# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*ខ្ញុំអត់ចេះរាយការណ៍ចោទប្រជាជនឯងនាំឲ្យគេចាប់ទេ!*

*អ្នកធ្លាប់រស់នៅជាមួយខ្ញុំនាពេលនោះ ឥឡូវរស់នៅភ្នំពេញរហូតដល់សព្វថ្ងៃ*

*ហើយអ្នកទាំងនោះនៅស្គាល់ខ្ញុំ។ ....បើសិនណាក្រៅពីជាមួយខ្ញុំ ទៅអស់ហើយ!*

សាក្សី **យុន គីម** ។

## I. ទិដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីពីររូប គឺលោក **យុន គីម**[1] និងលោក **ខៀវ នៅ**[2]។ សាក្សីទាំងពីរបានផ្តល់សក្ខីកម្មលើបទចោទប្រកាន់នានាដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២ ផ្ទុយពីសាក្សីមុនៗដែលការសួរដេញដោលត្រឹមតែផ្នែកកំណត់នៅក្នុងដីកាបំបែកដំណើរការនីតិវិធី[3]។

សាក្សី **យុន គីម** គឺជាមេឃុំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋាន - រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង - និងព្រឹត្តការណ៍កើតមាននៅក្នុងឃុំ

ស្រុករបស់ខ្លួន។ ទោះបីជាមានការរ៉ាយរ៉ាប់យ៉ាងលម្អិតនិងច្បាស់លាស់ក៏ដោយ ក៏ដំណើររឿងរបស់គាត់ហាក់ដូចជាផ្ទុះបញ្ចាំងពីចំណុចវិជ្ជមាននៃរបបកម្ពុជាប្រជាធិបតេយ្យ យោងតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់។

ចំណែកឯសាក្សី **ខៀវ នៅ** គឺជាអតីតព្រះសង្ឃ និងចូលរួមការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សក្ខីកម្មសំខាន់ៗរបស់គាត់ គឺផ្តែកលើ ៖ ការផ្សឹកព្រះសង្ឃក្រោយ "ថ្ងៃរំដោះភ្នំពេញ" នៅថ្ងៃ១៧ មេសា ១៩៧៥ - បទពិសោធន៍របស់គាត់ជាប្រធានផ្នែកដឹកជញ្ជូនពាណិជ្ជកម្មនៅភូមិភាគនិរតី (ស្ថិតក្រោមការគ្រប់គ្រងរបស់ តា **ម៉ុក**) - និងទំនាក់ទំនងជាមួយលោក **ខៀវ សំផន**។

មុនការប្រកាសសម្រាកសម្រាប់សវនាការសប្តាហ៍នេះ អង្គជំនុំជម្រះបានប្រកាសសេចក្តីព្រមានជាផ្លូវការណ៍មួយទៅក្រុមមេធាវីការពារក្តីលោក **នួន ជា** ចំពោះអកប្បកិរិយាមិនគោរពក្រមសីលធម៌វិជ្ជាជីវៈ ជាបន្ទាប់ ប្រកាសពីវិសម្មកាល ដែលសវនាការនឹងឈប់សម្រាករយៈពេល ៣សប្តាហ៍ និងចាប់ផ្តើមឡើងវិញនៅថ្ងៃទី១៦ កក្កដា ២០១២ មួយនឹងការផ្តល់សក្ខីកម្មរបស់សាក្សីជំនាញ បណ្ឌិត **ដេវីដ ឆេនដល័រ**។

## II. សេចក្តីសង្ខេបសក្ខីកម្មរបស់សាក្សី

សាក្សី **យុន គីម** មានឈ្មោះហៅក្រៅ "**ខាន់**" មានអាយុ ៧០ឆ្នាំ។ តួនាទីនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺជាកសិករ និងជាមេឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ។ លោក **សេង ប៊ុនឃាង** និង លោក **ដេល លីសាក់** ដែលជាតំណាងសហព្រះរាជអាជ្ញា បានចាប់ផ្តើមសួរដេញដោលសាក្សីនៅថ្ងៃអង្គារ។ នៅព្រឹកថ្ងៃបន្ទាប់ លោក **វ៉ែន ពៅ** និងលោកស្រី **អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត** ដែលជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានសួរដេញដោលសាក្សីនៅវគ្គទី១ និងចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** សួរសំណួរមួយចំនួននៅវគ្គទី២។ នៅសវនាការវគ្គទី៣ ដោយជនជាប់ចោទ **នួន ជា** ប៉ុនប៉ងធ្វើសេចក្តីថ្លែងការណ៍ ដូច្នេះ មេធាវី **សុន អរុណ** មេធាវី **អាង ឧត្តម** និងមេធាវី **អាកទួរ វែកគែន** បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន ដោយសួរតែពីរបីសំណួរប៉ុណ្ណោះទៅកាន់សាក្សី។

សាក្សីបានផ្តល់សក្ខីកម្ម អំពីសាវតារបស់ខ្លួន - តួនាទីរបស់លោក **នួន ជា** ក្នុងការបង្កើតសហករណ៍ នៅខេត្តក្រចេះ (តំបន់៥០៥) - រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង - ស្ថានភាពនៅក្នុងសហករណ៍ និងការដ្ឋានដែលសាក្សីបានគ្រប់គ្រង - ការចាប់ខ្លួន និងបោសសម្អាត - ការរៀបការដោយបង្ខំ - ការជម្លៀសដោយបង្ខំ - ការគោរពព្រះពុទ្ធសាសនា - និងការប្រព្រឹត្តលើជនជាតិភាគតិចចាម និងវៀតណាមនៅក្នុងតំបន់របស់គាត់។

ចំពោះសាក្សីទី២ លោក **ខៀវ នៅ** មានអាយុ៧៨ឆ្នាំ និងធ្លាប់ជាអតីតព្រះសង្ឃនៅខេត្តតាកែវ។ សព្វថ្ងៃនេះ សាក្សីចំណាយពេលវេលាស្ទើរតែទាំងអស់ មើលថែប្រពន្ធកូន និងជួយការងារវត្ត អារ៉ាម។ លោក **វ៉េង ហ៊ត់** និងលោក **តារីក អាប់ឌុលឡាក់** ដែលជាតំណាងសហព្រះរាជអាជ្ញា បានចាប់ផ្តើមសួរសាក្សីនៅរសៀលថ្ងៃពុធ រហូតដល់ថ្ងៃព្រហស្បតិ៍។ ចំណែកឯមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី **ពេជ្រ អង្គ** និង **បាណាបេ ណេគ្គី** ព្រមទាំងចៅក្រម **ឡាវ៉ែន** បានសួរដេញដោលនៅវគ្គទី៤។ ចំពោះក្រុមមេធាវីការពារក្តីទាំងបីក្រុម បានសម្រេចមិនសួរដេញដោលសាក្សីទេ។

### ក. សក្ខីកម្មរបស់សាក្សី យុន គីម

សាក្សី **យុន គីម** បានបង្ហាញថា គាត់បានចូលរួមចលនាបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧១ ក្រោយពីបានទទួលការណែនាំពីឈ្មោះ **ឈុន យ៉ង់** ហៅ "**ចេត**" ដែលជាលេខាបក្សក្នុងស្រុកសំបូរ។ នៅពេលនោះ ខ្មែរក្រហមបានរំដោះខេត្តក្រចេះហើយ។ សាក្សីភ័យខ្លាចថា "ប្រសិនបើខ្លួនមិនចូលរួមចលនាតស៊ូ ខ្លួននឹងអាចមានគ្រោះថ្នាក់នៅថ្ងៃណាមួយ"។ សាក្សីបានសម្រេចចូលរួម ដើម្បីយល់ឲ្យបានច្បាស់ពីបដិវត្តន៍ និង "ក្នុងការការពារខ្លួន និងការពារប្រជាជន"។ ជាដំបូង សាក្សីបម្រើការជាមេឃុំ នៅឃុំវឌ្ឍនៈ នៅឆ្នាំ១៩៧១។ នៅឆ្នាំ១៩៧៧ គាត់ត្រូវបានចាត់តាំងឲ្យធ្វើជាមេឃុំសំបូរ (ដែលជាឃុំធំ) បន្ទាប់មកឃុំស្រែឃឿន។ នៅខែមិថុនា ១៩៧៨ គាត់បានផ្លាស់ទៅការដ្ឋាន ប-៣។ សាក្សីជាមនុស្សម្នាក់ក្នុងចំណោមអ្នកដឹកនាំនានានៅខេត្តក្រចេះ ដែលបានរស់រានមានជីវិតពីការបោសសម្អាត នៅជិតការដួលរលំនៃរបបនោះ។

#### ១. តួនាទីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងនាមជាមេឃុំនៅទសវត្សន៍ឆ្នាំ១៩៧០ សាក្សីទទួលខុសត្រូវចម្បង ផ្តោតទៅលើកិច្ចការសេដ្ឋកិច្ច និងកសិកម្ម។ ថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យបានណែនាំគាត់ឲ្យយកចិត្តទុកដាក់លើប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាថា កសិកម្មអាចធ្វើទៅដោយសមស្រប។ បន្ថែមលើនេះ គាត់ក៏ជួយថែរក្សាសណ្តាប់ធ្នាប់ទូទៅ និងមើលការខុសត្រូវសុខភាពប្រជាជន។ នៅឯការដ្ឋាន ប-៣ សាក្សី **យុន គីម** មិនត្រឹមតែទទួលខុសត្រូវលើយុវជន ៧០០នាក់ ប៉ុណ្ណោះទេ ថែមទាំងឈូសឆាយរំលីងដី ១០០ហិចតា ដើម្បីធ្វើស្រែ។

សាក្សីបានផ្តល់សក្ខីកម្មថា ក្នុងនាមជាមេឃុំត្រូវតែគោរពតាមបទបញ្ជា។ ប្រសិនបើបទបញ្ជានោះពិបាកក្នុងការអនុវត្តន៍ពេក គាត់ព្យាយាម "ធ្វើឲ្យបន្ទុកនោះស្រាលជាងមុន" ដើម្បីឲ្យប្រជាជនអាចរស់រានបាន។ សាក្សីមានភាពជិតស្និតយ៉ាងខ្លាំងជាមួយប្រជាជន ពុំដូចថ្នាក់ដឹកនាំជាន់ខ្ពស់ទេ ដូច្នេះ គាត់អាចយល់ដឹងពីតម្រូវការរបស់ពួកគេ។ ការងាររបស់សាក្សី គឺធានាថា "ភូមិឃុំរបស់គាត់មានសុវត្ថិភាព និងមានអាហារទទួលទានគ្រប់គ្រាន់"។

សាក្សី **យុន គីម** បានបន្តថា គាត់បានអនុញ្ញាតឲ្យប្រជាជនបរិភោគបាយ ទោះបីជាមានបញ្ជាពីថ្នាក់លើ[4]ឲ្យប្រជាជនទទួលទានបបររាវៗ។ ហេតុផលរបស់គាត់គឺថា ៖

> *"ខ្ញុំហូបបាយរហូតពីព្រោះលទ្ធភាពរបស់ឃុំខ្ញុំ កន្លែងណាខ្ញុំនៅ ខ្ញុំអាចរកបាយជូនប្រជាជនហូបបាន ពីព្រោះបើហូបឆ្អែត វាខ្លាំងរហូតដែរហ្នឹង ប្រឡងប្រណាំងក្នុងខេត្តក្រចេះ ខ្ញុំមិនអួតទេ គ្មាននរណាធ្វើឈ្នះខ្ញុំទេ ព្រោះខ្ញុំឲ្យប្រជាជនហូបឆ្អែត។ ខ្ញុំនៅត្រង់ណាក៏អត់ហូបបបរ ដូច្នេះយើងមានឯករាជ្យម្ចាស់ការ"* ។

នៅឆ្នាំ១៩៧៦ មានការប្រឡងប្រណាំងរវាងឃុំនឹងឃុំ សាក្សីពុំបានរាយការណ៍ពីចំនួនទិន្នផលស្រូវទាំងអស់ទេ គាត់រាយការណ៍តែ ១១៣ថាំង (ចំនួនសរុប ១២៦ថាំង) ក្នុងគោលបំណងឲ្យឃុំរបស់គាត់មានស្បៀងបន្ថែម។ ជាទូទៅ ពុំមានរបាយការណ៍ពីកង្វះខាតស្រូវអង្ករ ក៏ប៉ុន្តែនៅសហករណ៍ផ្សេងឲ្យប្រជាជនបរិភោគបបរ គឺតាមបញ្ជារបស់ថ្នាក់លើ។[5]

ផ្អែកតាមសាក្សី **យុន គីម** គាត់ព្យាយាមការពារសមាជិកនៅក្នុងឃុំរបស់គាត់ មិនឲ្យគេចាត់ទុកថាជាខ្មាំងសត្រូវទេ។ សាក្សីបានប្រមើលឃើញថា ប្រសិនបើប្រជាជនរាយការណ៍ដាក់គ្នាទៅវិញទៅមក ពួកគេអាចនឹងត្រូវសម្លាប់ ដូច្នេះ គាត់បានណែនាំឲ្យប្រជាជនរក្សាសារតាខ្លួន និងមិនឲ្យរាយការណ៍ដាក់គ្នាទៅវិញទៅមក។ បន្ថែមលើនេះ សាក្សី **យុន គីម** បានរៀបចំរបាយការណ៍មិនពិតចំពោះមនុស្សដែលត្រូវជាប់ "សង្ស័យ" (ឧទា ៖ អតីតមេឃុំ ទាហាន **លន់ នល់** ជាដើម) ដើម្បីការពារពួកគេពីការចាត់ទុកជាខ្មាំង។ សាក្សីទទួលការរិះគន់នៅថ្នាក់ស្រុក ព្រោះការមិនរាយការណ៍ពីស្ថានភាពខ្មាំងសត្រូវ ប៉ុន្តែគាត់បានផ្តល់ហេតុផលថា វាពិបាកក្នុងការរាយការណ៍ពីបញ្ហានេះណាស់ ព្រោះនៅក្នុងស្រុកភូមិគាត់មានតែប្រជាជនធ្វើការ។ សាក្សីបានលើកថា ប្រជាជនរស់នៅជាមួយគាត់ សុទ្ធតែរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ៖ *"រស់នៅជាមួយខ្ញុំ ខ្ញុំអត់ចេះដែលរាយការណ៍ចោទប្រជាជនឯងនាំឲ្យគេចាប់ទេ ...បើសិនណាជាក្រៅពីជាមួយខ្ញុំទៅអស់ហើយ!"*។

នៅពេលសាក្សីរៀបរាប់ពីរបៀបដែលគាត់បានព្យាយាមផ្គត់ផ្គង់អាហារ និងការពារជីវិតប្រជាជននៅក្នុងសហករណ៍របស់គាត់ ចៅក្រម **ឡាវែន៍** បានចោទសួរសាក្សីដោយដាក់បង្ហាញនូវសេចក្តីថ្លែងការណ៍របស់អតីតសមាជិកកងឈ្លបខ្មែរក្រហមម្នាក់ បានអះអាងថា គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅភូមិកែងប្រាសាទ (ស្ថិតនៅក្នុងឃុំស្រែឃឿន និងឃុំសំបូរ) នៅខែកក្កដា ១៩៧៦។ អតីតកម្មាភិបាលរូបនេះ បានរៀបរាប់ពីការរស់នៅដោយលំបាកវេទនានៅក្នុងឃុំនេះ ៖

> *ពួកគេបានបង្ខំឲ្យពួកយើងធ្វើការទាំងយប់ទាំងថ្ងៃ ធ្វើស្រែ ធ្វើចម្ការ ធ្វើការសព្វគ្រប់បែបយ៉ាង ៖ ឃ្វាលគោក្របី ដាំបន្លែបង្ការ គឺអត់មានពេលទំនេរទេ... ការហូបចុកមិនគ្រប់គ្រាន់ និងហូបរួម។ ពេលខ្លះ បានបាយមួយពេល ឬបបរមួយពេលតែប៉ុណ្ណឹង!*

សេចក្តីថ្លែងការណ៍របស់កម្មាភិបាលរូបនេះ បានបង្ហាញថា នៅចុងឆ្នាំ១៩៧៦ ឬ ១៩៧៧ ប្រជាជន ១៧ មេសា មកពីខេត្តកំពង់ចាម បានមកដល់ឃុំនេះ ព្រមទាំង "ប្រជាជនមកពីបូព៌ា ដែលខ្លះបានស្លាប់ដោយអត់អាហារ និងខ្លះទៀតស្លាប់ដោយខ្វះថ្នាំសង្កូវ"។ ជាការឆ្លើយតប សាក្សី **យុន គីម** បានបដិសេធចំពោះ

សេចក្តីថ្លែងការណ៍របស់អតីតកម្មាភិបាលរូបនេះ និងបញ្ជាក់ថា គាត់ពិតជាអ្នកមើលការខុសត្រូវសហករណ៍ស្រែឃឿនប្រាកដមែន។

ជាបន្ទាប់ ចៅក្រម **ឡាវែន៍** បានអានសេចក្តីថ្លែងការណ៍របស់ជនជាតិចាមម្នាក់ ដែលគាត់ត្រូវបានបញ្ជូនទៅឃុំសំបូរផងដែរ។ ផ្អែកតាមសេចក្តីថ្លែងការណ៍ នៅពេលគាត់បានមកដល់ឃុំសំបូរ គ្រួសាររបស់គាត់ត្រូវបានណែនាំឲ្យទៅរស់នៅជាមួយប្រជាជនចាស់។ គាត់ក៏បានរៀបរាប់ពីការធ្វើការដោយឥតឈប់ឈរនៅក្នុងសហករណ៍ ៖

> *"យើងចាប់ផ្តើមធ្វើការពីម៉ោង ៣ព្រឹក រហូតដល់ម៉ោង ១១ថ្ងៃត្រង់ បន្ទាប់សម្រាកហូបបាយ។ បន្ទាប់មកបន្តការងារនៅម៉ោង ១ថ្ងៃត្រង់ រហូតដល់ ៥ល្ងាច និងសម្រាកអាហារពេលល្ងាច។ យើងបន្តបោកបែនស្រូវពីម៉ោង ៦ល្ងាច រហូតដល់ម៉ោង ៩យប់ ទើបអាចសម្រាកចូលគេងបាន"*។

សេចក្តីថ្លែងការណ៍នេះ គឺផ្ទុយពីសក្ខីកម្មរបស់សាក្សី។ សាក្សីបានឆ្លើយថា គាត់មិនធ្លាប់ដឹងថាមានមនុស្សធ្វើការធ្ងន់ធ្ងរបែបនេះទេ ហើយក៏មិនបានដឹងថាមានអ្វីកើតឡើងចំពោះជនជាតិចាមដែរ។

### ២. រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង

ក្នុងនាមកម្មាភិបាលថ្នាក់ទាប សាក្សីយល់ដឹងត្រឹមតែ ៖ ស្ថានភាពភូមិសាស្ត្រ - រចនាសម្ព័ន្ធរដ្ឋបាល - ទំនាក់ទំនង - និងការគ្រប់គ្រងនៅតំបន់៥០៥ ជាពិសេស នៅថ្នាក់ឃុំ និងស្រុករបស់គាត់។ សាក្សីយល់ដឹងខ្លះៗពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនៅក្នុងតំបន់ខ្លួន។

### ក. ខេត្តក្រចេះ

ខេត្តក្រចេះ ឬហៅថា តំបន់៥០៥ ត្រូវបាន "រំដោះ" ប្រហែលជា ២ខែ ក្រោយពីរដ្ឋប្រហារ **លន់ នល់** នៅឆ្នាំ១៩៧០។ ខេត្តក្រចេះត្រូវបានបែងចែកជា ៣ស្រុក ៖ ស្រុកសំបូរ ស្រុកស្នួល និងស្រុកក្រចេះ។ នៅឆ្នាំ១៩៧៦ ឬ ១៩៧៧ តំបន់នេះបានផ្តាច់ចេញពីភូមិភាគឦសាន និងក្លាយជាតំបន់ស្វយ័ត ដែលមាន

អំណាចរាយការណ៍ផ្ទាល់ទៅគណៈមជ្ឈឹមនៅភ្នំពេញ។ នៅក្នុងចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត សាក្សី **យុន គីម** បានរ៉ាយរាប់ឈ្មោះលេខាតំបន់ ៥០៥ ដូចតទៅ ៖ តា **យឹម** (១៩៧១ ទៅ ១៩៧៦) តា **យ៉ុ** (១៩៧៦ ទៅដើម ១៩៧៨) និង **មឿន** (កាល បរិច្ឆេទមិនជាក់លាក់)។ តំបន់៥០៥មានមុខងារជាមន្ទីរសន្តិសុខ ពុំមែនជាបន្ទាយទាហានចាប់ចងប្រជាជននោះទេ។

***ស្រុកសំបូរ ៖*** នៅមុនឆ្នាំ១៩៧៩ ស្រុកសំបូរមានឃុំ៩ គឺ ឃុំវឌ្ឍនៈ ឃុំសណ្ដាន់ ឃុំរកាខ្នុរ ឃុំបឹងចារ ឃុំកំពង់ចាម ឃុំក្បាលដំរី ឃុំអូរក្រៀង ឃុំស្រែជិះ និងឃុំសំបូរ។ សាក្សី **យុន គីម** បានថ្លែងថា **តាចែត្រ** ជាថ្នាក់ដឹកនាំស្រុកសំបូរ ក្រោយមកជំនួសដោយ **ផាន**[6] បន្ទាប់មកទៀត **នី** ។ ក្រោយពីការចាប់ខ្លួន **នី** នៅឆ្នាំ១៩៧៨ **វឿន** ដែលជាកម្មាភិបាលមកពីផ្នែកយោធា បានជំនួសតំណែងរបស់ **នី** រហូតដល់ពេលវៀត-ណាមចូលនៅឆ្នាំ១៩៧៩។

### ខ. អំពីឃុំ

សាក្សី **យុន គីម** បានរៀបរាប់ថា គណៈឃុំ រួមមាន មេឃុំជាប្រធាន អនុប្រធាន (ទទួលបន្ទុកខាងយោធា) និងសមាជិក ៣រូបទៀត ដែលរាប់រងខាងសេដ្ឋកិច្ច សន្តិសុខ និងបញ្ហាសង្គម។ មន្ទីរយោធាគឺមើលការខុសត្រូវសន្តិសុខនៅនឹងកន្លែង រីឯផ្នែកសន្តិសុខរាយការណ៍ពីព្រឹត្តការណ៍នៅក្នុងឃុំទៅថ្នាក់លើ។ ចំណែកផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម សាក្សីមិនបានពន្យល់ទេ។

### គ. ទំនាក់ទំនង និងកិច្ចប្រជុំ

តាមឋានានុក្រម គណៈឃុំរាយការណ៍ទៅស្រុក ក្នុងនាមខ្លួនជាមេឃុំ សាក្សីបានរាយការណ៍ផ្ទាល់ទៅថ្នាក់ស្រុកនៅក្នុងកិច្ចប្រជុំ។ នៅថ្នាក់ស្រុកមានរៀបចំជាកិច្ចប្រជុំប្រចាំសប្ដាហ៍ ដែលមេឃុំគ្រប់រូបបានចូលរួម និងរាយការណ៍ពី “ស្ថានភាពខ្មាំង” - ជម្លោះប្រឆាំងនឹងបដិវត្តន៍ - ផលិតផល - និងសុខភាពប្រជាជន។ ភាពខ្ជិលច្រអូសនឹងការងារ - ធ្វើការមិនយកចិត្តទុកដាក់ - ឬការនិយាយខុសឆ្គង ក៏ត្រូវបានរាយការណ៍ដែរ។ សាក្សីពុំបានដឹងថាតើថ្នាក់ស្រុកបានរបាយការណ៍ទៅថ្នាក់លើដោយរបៀបណាទេ ប៉ុន្តែជាសន្និដ្ឋាន នីរសារគឺជាអ្នកបញ្ជូនឯកសារពីកន្លែងមួយទៅកន្លែងមួយ។

បន្ថែមលើនេះ សាក្សីបានចូលរួមវគ្គប្រជុំប្រចាំឆ្នាំ ដែលប្រព្រឹត្តទៅពី ១៥ ទៅ ២០ថ្ងៃ រៀបចំឡើងនៅទីរួមខេត្ត។ នៅក្នុងកិច្ចប្រជុំ សាក្សីបានជួបលេខាតំបន់នានា ។ ចំណែកឯ គណៈស្រុក - អនុស្រុក - កម្មាភិបាលធ្វើការនៅខេត្ត - យោធា - និងគណៈភូមិ ពេលខ្លះក៏បានចូលរួមផងដែរ។ នៅក្នុងវគ្គសិក្សានេះ សេចក្ដីណែនាំបក្ស គឺផ្ដោតសំខាន់តាមមាត្រាដែលមានចែងនៅក្នុងទស្សនាវដ្ដី *ទង់បដិវត្តន៍* គឺជា "ឯកសារស្នូលសម្រាប់... បទដ្ឋាន និងសេចក្ដីណែនាំនានា"។

### ៣. សហករណ៍ និងការដ្ឋាន

សាក្សីបានរៀបរាប់អំពីកិច្ចប្រជុំបង្កើតសហករណ៍ (ធ្វើឡើងដោយជនជាប់ចោទ **នួន ជា**) ព្រមទាំងអំពីទម្រង់ និងព្រឹត្តការណ៍នៅកន្លែង ដែលគាត់បានធ្វើជាប្រធាន។

#### ក. ជនជាប់ចោទ នួន ជា និងការបង្កើតសហករណ៍នៅខេត្តក្រចេះ

សាក្សីបានរ៉ាយរ៉ាប់ថា គាត់បានជួបលោក **នួន ជា** តែម្ដងគត់ នៅក្នុងកិច្ចប្រជុំមួយរៀបចំឡើងសម្រាប់មេឃុំ នៅឆ្នាំ១៩៧៣ ដែលពិភាក្សាអំពីការបង្កើតសហករណ៍នៅខេត្តក្រចេះ។ សាក្សីចងចាំថា បងធំទី២ មេដឹកនាំខ្មែរ ក្រហម គឺជាមនុស្ស "មានសណ្ដានចិត្តល្អនៅក្នុងជួរដឹកនាំ"[7]។

ជនជាប់ចោទ **នួន ជា** បានថ្លែងនៅក្នុងឱកាសនោះថា សហករណ៍គួរត្រូវបង្កើតឡើង និងបានណែនាំមេឃុំ អំពីការបង្កើតសហករណ៍លើ ៣ជំហាន។ ជាដំបូង ជនជាប់ចោទបានណែនាំពីការបង្កើត "ក្រុមប្រវាស់ដៃ" គឺជាក្រុមដែលមានពីសមាជិកពី ៥ ទៅ ១០គ្រួសារ ជួយគ្នាទៅវិញទៅមក និងធ្វើកសិកម្មនៅលើដីរៀងៗខ្លួន។ បន្ទាប់ពីក្រុមប្រវាស់ដៃទទួលបានជោគជ័យលោក **នួន ជា** បានណែនាំពួកគាត់ឲ្យចាប់ផ្ដើមអនុវត្ត "សហករណ៍កម្រិតទាប" ក្រុមនេះគឺមានភាពស្រដៀងគ្នាទៅនឹងក្រុមប្រវាស់ដៃដែរ ពីព្រោះប្រជាជននៅតែមានកម្មសិទ្ធិលើដីធ្លី និងគោក្របីរបស់ខ្លួន។ ចំណែកចំណុចខុសប្លែកគ្នា គឺថា ផលិតផល និងការបែងចែកកម្លាំងពលកម្ម អាស្រ័យទៅលើចំនួនឧបករណ៍ និងសត្វពាហនៈនៅក្នុងសហករណ៍នោះ។ ក្រោយមកជនជាប់ចោទ **នួន ជា** បានណែនាំដល់មេឃុំថា "សហករណ៍កម្រិតខ្ពស់" អាចចាប់ផ្ដើមនៅពេលប្រជាជនបានយល់ដឹងពីទស្សនៈនៃទ្រព្យសម្បត្តិសមូហភាព។ ជនជាប់ចោទ **នួន ជា** បានបញ្ជាក់ថា មេឃុំមិនគួរបង្កើត "សហគមន៍" ព្រោះសហគមន៍ គឺមានលក្ខណៈស្រដៀងនឹងសហករណ៍ដែរ (ប្រជាជនធ្វើការរួម និងហូបរួម)

។ ចំណែកភាពខុសប្លែក ប្រជាជននៅក្នុងសហគមន៍មិនបែងចែកផលិតផល ដែលបានមកពីកម្លាំងពលកម្មខ្លួន។ ក្រោយពីការណែនាំរបស់លោក **នួន ជា** ដំណើរការបង្កើតសហករណ៍ត្រូវ បានអនុវត្តជាបន្តបន្ទាប់នៅតាមស្រុកនីមួយៗ។

ទោះបីជាមានការណែនាំរបស់លោក **នួន ជា** មិនឲ្យបង្កើតសហគមន៍ក៏ដោយ ក៏ឈ្មោះ **ចៃត្រ** (លេខាស្រុកសំបូរ) ពុំអនុវត្តតាមការណែនាំ និងបញ្ជាឲ្យបង្កើតសហគមន៍នៅក្នុងស្រុករបស់ខ្លួន។ សហគមន៍នៅស្រុកសំបូរ គឺរួមបញ្ចូលទាំងឃុំវឌ្ឍនៈ ហើយរចនាសម្ព័ន្ធនេះបានរក្សារហូតដល់ឆ្នាំ១៩៧៩។ ត្រង់ចំណុចនេះ សក្ខីកម្មរបស់សាក្សីមិនសូវច្បាស់ទេ នៅពេលនិយាយសំដៅសហករណ៍ គាត់បន្តលើកថា ឃុំវឌ្ឍនៈ និងឃុំសំបូរ គឺជាឃុំមួយ និងជាសហករណ៍មួយ។

**ខ. ឃុំវឌ្ឍនៈ**

វឌ្ឍនៈ គឺជាឃុំដែលទើបបង្កើតថ្មីនៅក្នុងស្រុកសំបូរក្នុងឆ្នាំ១៩៧១[៩]។ នៅថ្ងៃទី៤ មិនា ១៩៧១ គណៈស្រុកបានតែងតាំងសាក្សី **យុន គីម** ជាមេឃុំវឌ្ឍនៈ រហូតដល់គាត់ផ្លាស់ទៅឃុំសំបូរនៅឆ្នាំ១៩៧៧។ នៅឆ្នាំ១៩៧៦ ឃុំរបស់គាត់បានប្រមូលទិន្នផលស្រូវជាង ៣តោន ក្នុង ១ហិចតា ប៉ុន្តែស្រូវអង្ករស្ទើរតែទាំងអស់ត្រូវបានដឹកជញ្ជូនចេញ ហើយប្រជាជនហូបតែបបរ។ យ៉ាងណាមិញសាក្សីមិនបានដឹងពីទីកន្លែង ដែលស្រូវអង្ករដឹកបញ្ជូនចេញទៅទេ។

**គ. ឃុំសំបូរ**

នៅខែកុម្ភៈ ១៩៧៧ ក្រោយពីបានសម្រាកព្យាបាល "ច្រមុះហើម" នៅមន្ទីរពេទ្យភ្នំពេញ សាក្សីត្រូវបានបញ្ជូនទៅឃុំសំបូរវិញ ដោយសារ "ស្ថានភាពច្របូកច្របល់"។ សមាជិកគណៈឃុំសំបូរត្រូវបានចាប់ខ្លួនទាំងអស់ ដូច្នេះ មេស្រុក **ផាន** បានសុំជំនួយពីគាត់។ នៅពេលសាក្សី **យុន គីម** ត្រឡប់មកដល់ឃុំវិញ ថ្នាក់ស្រុកបានចាត់ឲ្យគាត់កំណត់ពីចំណាត់ថ្នាក់ប្រជាជនជា ៣ប្រភេទ ៖ ប្រជាជនចាស់ (សមាជិកសហករណ៍) សមាជិកត្រៀម (ប្រជាជនចាស់មកពីគ្រួសារខ្ពង់ខ្ពស់ ឬអ្នកមិនពេញចិត្តនឹងធ្វើបដិវត្តន៍) និង "ប្រជាជនបញ្ញើ" (ដូចជា ប្រជាជន ១៧មេសា ឬអ្នកត្រូវជម្លៀសចេញពីទីក្រុង)។ ផ្ទុយទៅវិញ សាក្សីបដិសេធថា គាត់មិនធ្លាប់ធ្វើការបែងចែកប្រជាជនទេ គឺការពារមិនឲ្យប្រជាជនចាស់មើលងាយមើលថោកប្រជាជនបញ្ញើ។ ថ្វីបើសក្ខី

កម្មរបស់សាក្សីបានបង្ហាញថា ការមិនស្តាប់បង្គាប់ថ្នាក់លើអាចបណ្តាលឲ្យមានការដាក់ពិន័យ ប៉ុន្តែមេធាវីមិនបានសួរសាក្សី ថាតើការមិនគោរពបញ្ជាមិនធ្វើចំណាត់ថ្នាក់ មិនត្រូវបានដាក់ពិន័យដោយរបៀបណា។

ឃុំសំបូរ គឺមាន៨ភូមិ។ នៅពេលឃុំបានបំបែកជា សហករណ៍ពីរ (សហករណ៍សំបូរ និងសហករណ៍ស្រែឃឿន) សហករណ៍ថ្មីនីមួយៗមាន ៤ភូមិ និងមានសមាជិកគណៈកម្មាធិការ ៣នាក់ ក្នុងការទទួលការខុសត្រូវ។ សាក្សីបានក្លាយជាប្រធានសហករណ៍ស្រែឃឿន គាត់បានគ្រប់គ្រងប្រជាជន ប្រហែលជា ៣,០០០នាក់។

### ឃ. ការដ្ឋាន ប-៣

សាក្សី **យុន គីម** បានជម្រាបដល់អង្គជំនុំជម្រះថា ការដ្ឋាន ប-៣ គឺជាអតីតគុកមួយសម្រាប់ដាក់កម្មាភិបាលដែលចាប់ខ្លួន។ នៅខែមេសា ១៩៧៨ អ្នកទោសទាំងនោះត្រូវបានបញ្ជូនទៅកន្លែងថ្មីដែលមិនបញ្ចេញឈ្មោះ ហើយយុវជនក្មេងៗត្រូវបានយកទៅដាក់នៅការដ្ឋាន ប-៣ ជំនួសវិញ។ ដំបូងឡើយ ការដ្ឋាន ប-៣ ស្ថិតក្រោមការគ្រប់គ្រងរបស់យោធា។ នៅថ្ងៃទី១១ មិថុនា ១៩៧៨ ឈ្មោះ **វឿន** ដែលជាលេខាស្រុកថ្មីមកពីយោធា បានបញ្ជាឲ្យគាត់គ្រប់គ្រងការដ្ឋាន ប-៣។ នៅពេលគាត់ទៅដល់ការដ្ឋាន យុវជនប្រហែលជា ៤៥០នាក់ បានរស់នៅក្នុងកូនខ្ទមជាង ៥០ ដែលខ្ទមនីមួយៗដាក់មនុស្សជាង ១០នាក់។ នៅទីនោះមានពេទ្យប្រចាំការ ២នាក់ សម្រាប់ព្យាបាលប្រជាជន ប្រសិនបើកើតជម្ងឺគ្រុនចាញ់។

សាក្សីត្រូវបានតម្រូវឲ្យធ្វើស្រែជាង ១០០ហិចតា និងដោយពួកគេមានតែពូថៅ និងប៉ែល ដូច្នេះគាត់បានស្នើសុំជាងដែក និងស្នើសុំដំរី ៣០ ទៅ ៤០ក្បាល ក្នុងការរំលីងដី ប៉ុន្តែដំរីតែជាង ១២ក្បាល ប៉ុណ្ណោះត្រូវបានប្រគល់ឲ្យ។ នៅពេលគាត់ស្នើសុំកម្លាំងបន្ថែម យុវជនជាង ២៥០នាក់ បានបញ្ជូនមកពីឃុំតាម្លូង ស្រុកមេមត់ ខេត្តកំពង់ចាម (ភូមិភាគបូព៌ា) ឲ្យជួយធ្វើកសិកម្មនៅការដ្ឋាន ប-៣ ឈូសឆាយរំលីងដី។ យុវជននៅការដ្ឋាន ប-៣ ត្រូវបានចោទប្រកាន់ថា មានជាប់សម្ព័ន្ធភាពជាមួយជនជាតិវៀតណាម ព្រោះតំបន់ដែលពួកគេរស់នៅ គឺនៅជិតព្រំប្រទល់វៀតណាម។ យុវជនទាំងនេះស្នាក់នៅការដ្ឋាន ប-៣ តែ ៣ខែ ប៉ុណ្ណោះ ក្រោយមកបញ្ជូនទៅខេត្តកំពង់ចាម។

### ៤. ការចាប់ខ្លួន ការរៀនសូត្រឡើងវិញ និងការបោសសម្អាត

សក្ខីកម្មរបស់សាក្សី **យុន គីម** បានឲ្យដឹងថា ការចាប់ខ្លួនកម្មាភិបាលនៅក្នុងតំបន់របស់គាត់។ កម្មាភិបាលភាគច្រើនត្រូវបានចាប់ខ្លួននៅក្នុងកិច្ចប្រជុំ។ ពាក្យស្លោករបស់បក្សកុម្មុយនីស្តកម្ពុជា *"ជីកស្មៅត្រូវជីកទាំងឫស"* មានន័យថា ប្រសិនបើកម្មាភិបាលម្នាក់ត្រូវចាប់ខ្លួន មនុស្សដែលមានទំនាក់ទំនងជាមួយបុគ្គលនោះក៏ត្រូវចាប់ខ្លួនដែរ ដូចជា ករណីនៅតំបន់៥០៥។

នៅពេលមានមនុស្សត្រូវបានចាប់ខ្លួន គាត់មិនដែលពិភាក្សាបញ្ហានេះ ឬសម្តែងការព្រួយបារម្ភរបស់គាត់ចេញមកក្រៅឡើយ គឺរក្សាជាការសម្ងាត់ ព្រោះគាត់ដឹងថា ប្រសិនបើគាត់ ឬកម្មាភិបាលឋានៈ ដូចគ្នាបាននិយាយពីបញ្ហានេះ ពួកគេនឹងចាប់ផ្តើមបាត់បង់ទំនុកចិត្តគ្នាទៅវិញទៅមក និងមានការរាយការណ៍ពីរូបគាត់ ដែលធ្វើឲ្យស្ថិតក្នុងសភាពគ្រោះថ្នាក់ (អាចមានការចាប់ខ្លួន)។

### ក. ការចាប់ខ្លួនមុនឆ្នាំ១៩៧៨

សាក្សីចងចាំថា នៅឆ្នាំ១៩៧៦ ឈ្មោះ **ចែត្រ** ដែលជាអតីតថ្នាក់លើរបស់គាត់នៅស្រុកសំបូរ ត្រូវបានចាប់ខ្លួន[9]។ ឈ្មោះ **បាន សារុន** ហៅ "កង" ដែលជាប្រធានសន្តិសុខតំបន់៥០៥ ក៏ត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១[10]។ បន្ថែមលើនេះ តា **ឈី** ដែលជាអតីតមេឃុំ ក៏ត្រូវបានបាត់ខ្លួន បន្ទាប់ពីមានបញ្ជាពីគណៈស្រុក ឲ្យរឹបអូសសម្ភារៈរបស់គាត់យកទៅមន្ទីរស្រុក។ សាក្សីជឿជាក់ថា គាត់ត្រូវបានផ្ទេរទៅឃុំសំបូរ ដោយសារសមាជិកគណៈកម្មាធិការឃុំនោះត្រូវបានចាប់ខ្លួនអស់។ តា **ខិន** ដែលជាមនុស្សធ្វើការនៅថ្នាក់ស្រុក និងក្រោយមកធ្វើនៅផ្នែកសេដ្ឋកិច្ចថ្នាក់តំបន់ ក៏ត្រូវបានចាប់ខ្លួនដែរ។

### ខ. ការបោសសម្អាតថ្នាក់តំបន់នៅឆ្នាំ១៩៧៨

សាក្សី **យុន គីម** បានរៀបរាប់ពីស្ថានភាពក្នុងខេត្តក្រចេះ នៅដើមឆ្នាំ១៩៧៨ ថា "ច្របូកច្របល់ណាស់" ដោយសារការកាន់កាប់របស់ទាហាននៅតំបន់នោះ។ ការចាប់ខ្លួនត្រូវបានធ្វើឡើងនៅគ្រប់ជាន់ថ្នាក់ ៖ គណៈខេត្ត សមាជិកជាច្រើននៃគណៈកម្មាធិការស្រុក គណៈឃុំ និងសូម្បីតែទាហានថ្នាក់តំបន់។ លេខាតំបន់ឈ្មោះ **យ៉ី** ត្រូវបានចាប់ខ្លួនលើទូក នៅពេលធ្វើដំណើរទៅភ្នំពេញ។ ចំណែកឯឈ្មោះ **ក្អួន** ដែលជាអនុលេខាតំបន់ និងមេបញ្ជាការយោធាថ្នាក់តំបន់ ក៏ត្រូវបានចាប់ខ្លួនដែរ។ នៅក្នុងបញ្ជីរបស់មន្ទីរ ស-២១ កម្មាភិបាលទាំងពីរខាងលើ និងប្រពន្ធពួកគេត្រូវបានបញ្ជូន និងជាប់ឃុំនៅមន្ទីរ ស-២១[11]។ នៅស្រុកសំបូរ ឈ្មោះ **ភឿន**

ដែលជាប្រធានសន្តិសុខថ្នាក់ស្រុក និងឈ្មោះ **នី** ដែលជាលេខាស្រុក ក៏ត្រូវបានចាប់ខ្លួនដែរ ប៉ុន្តែក៏មានសមាជិកគណៈកម្មាធិការមួយចំនួនអាចលាក់ និងរត់គេចខ្លួនរួច។ ឈ្មោះ **នី** និង **ភឿន** ក៏ព្យាយាមគេចខ្លួនដែរ ប៉ុន្តែនៅពេលមានការកោះហៅឲ្យត្រឡប់មកវិញ ពួកគេក៏ព្រមចូលខ្លួន ដូច្នេះក៏ត្រូវចាប់ខ្លួននៅក្នុងកិច្ចប្រជុំនោះ។ នៅពេលឃើញឯកសារនៅមន្ទីរ ស-២១ សាក្សីបានបញ្ជាក់ថា ឈ្មោះនៅក្នុងបញ្ជីនេះ ពិតជាបុគ្គលឈ្មោះ **នី** និង **ភឿន** ប្រាកដមែន។ ចំណែកឈ្មោះ **ផាន** ដែលជាមេស្រុក ក៏មានជោគវាសនាដូចគ្នាដែរ។

ឆ្លើយតបទៅសំណួរពាក់ព័ន្ធនឹងមូលហេតុនៃការចាប់ខ្លួន សាក្សីបានឲ្យដឹងថា ប្រជាជនដែលត្រូវចាប់ខ្លួន គឺជាទូទៅត្រូវបានចោទប្រកាន់ និងសង្ស័យថា ជាជនក្បត់ ប៉ុន្តែគាត់មិនជឿថា មនុស្សគ្រប់រូបជាជនក្បត់ទេ ជាពិសេស ឈ្មោះ **ផាន** និងឈ្មោះ **នី** ពួកគេជាមនុស្សល្អ។

### គ. មន្ទីរសន្តិសុខ

សាក្សី **យ៉ុន គីម** បានថ្លែងថា មានមន្ទីរសន្តិសុខពីរនៅស្រុកសំបូរ គឺមន្ទីរសន្តិសុខព្រះស្រាល និងមន្ទីរសន្តិសុខគោកក្តួច។ មន្ទីរសន្តិសុខព្រះសាល គឺជាមន្ទីរសម្រាប់ឃុំឃាំងមនុស្សដែលប្រព្រឹត្តកំហុសតូចតាច ហើយអ្នកជាប់ឃុំត្រូវឲ្យធ្វើកសិកម្ម។ ផ្ទុយទៅវិញ ចំពោះមន្ទីរសន្តិសុខគោកក្តួច សាក្សីពុំបានដឹងពីស្ថានកំហុសបែបណាទេ ព្រោះមនុស្សដែលជាប់ឃុំនៅទីនោះ មិនដែលរួចមានជីវិតត្រឡប់មកវិញឡើយ។ ឈ្មោះ **អ៊ុង សាម៉ុន** (ប្រធានឃុំវឌ្ឍនៈ និងប្រធានមន្ទីរសន្តិសុខនៅស្រុកសំបូរ) ឈ្មោះ **ឈាន** (ជាអ្នកជំនួស **អ៊ុង សាម៉ុន**) និងឈ្មោះ **ឈុន** (ជាប្រធានឃុំវឌ្ឍនៈចាស់) ពួកគេត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខគោកក្តួច។

ចំពោះមន្ទីរសន្តិសុខ ប-៣ (ដែលក្រោយមកផ្លាស់ឈ្មោះជាការដ្ឋាន ប-៣) គឺជាមន្ទីរសន្តិសុខថ្នាក់ខេត្តសម្រាប់អប់រំកែប្រែកម្មាភិបាលថ្នាក់ស្រុក និងថ្នាក់ឃុំ។ នៅមុនពេលសាក្សីមកកាន់ដំណែងជាប្រធាននៅមន្ទីរនេះ គាត់ពុំបានដឹងថាមានមន្ទីរនេះទេ។ អ្នកជាប់ឃុំត្រូវឲ្យធ្វើស្រែចម្ការ និងការងារនានានៅក្នុងសហករណ៍។

### ៥. ការរៀបការដោយបង្ខំ

សាក្សីបានរៀបរាប់ថា នៅតំបន់របស់គាត់ គឺពុំមានការបង្ខំឲ្យរៀបការទេ។ ការរៀបការ គឺមានការយល់ព្រមពីសាមីភាគី (កូនក្រមុំនិងកូនកម្លោះ) មុននឹងមានពិធីកើតឡើង។ នៅពេលសាក្សីក្លាយជាប្រធានឃុំវឌ្ឍនៈ មានទាហានមួយចំនួនបានស្នើសុំគណៈស្រុកឲ្យជ្រើសរើសនារី ៣០រូប រៀបការជាមួយខ្លួន។ ថ្នាក់ស្រុកបានបញ្ជូនព័ត៌មាននេះមកគាត់ និងឲ្យចាត់ចែង "ស្វែងរកនារីស្ម័គ្រចិត្ត" នៅក្នុងសហករណ៍របស់គាត់ មាននារី ២៥រូប បានស្ម័គ្រចិត្ត ហើយទាហានបានមកទទួលយកពួកគេ។

សាក្សី **យ៉ុន គីម** បានបន្តថា ពេលខ្លះ ទាហានបានធ្វើសំណើដោយផ្ទាល់ទៅថ្នាក់លើដម្រាបពីឈ្មោះស្ត្រី ដែលខ្លួនមានបំណងចង់រៀបការជាមួយ[12]។ នៅក្នុងពិធីមង្គលការ កូនកម្លោះកូនក្រមុំមានពាក់ផ្កាកលេខសម្គាល់ ដោយសារតែមានគូស្រករជាច្រើននៅក្នុងពិធីនោះ។ សាក្សីធ្លាប់បានឃើញគូស្រករចំនួន ១០គូ បានរៀបពិធីជាមួយគ្នា នាពេលនោះពួកគេពិតជាបានពាក់ផ្កាកលេខសម្គាល់ (គូស្រករនីមួយៗមានលេខសម្គាល់ដូចគ្នា)។ សាក្សីពុំបានដឹងថា នេះជាការរៀបការដោយបង្ខំ។

**៦. ការជម្លៀសដោយបង្ខំ**

សាក្សីបានឲ្យដឹងថា គាត់ពុំបានដឹងពីការជម្លៀសប្រជាជននៅក្នុងតំបន់របស់គាត់ទេ។ ជនជាតិចាមដែលបានមកដល់ឃុំវត្តន្ទះនៅមុនឆ្នាំ១៩៧៥ គឺមានតែ៣០ ទៅ ៤០គ្រួសារប៉ុណ្ណោះ ពួកគេមកពីឃុំស្វាយកាំបិត។ ចំណែកឯការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ គាត់បានដឹងនៅពេល "ប្រជាជនថ្មី" មកដល់តំបន់ខ្លួនគាត់ ពួកគេមកតាមទូក។ នៅឆ្នាំ១៩៧៨ ប្រជាជនជាច្រើនត្រូវបានបញ្ជូនពីស្រុកមេម៉ត់ ដែលជាតំបន់ជាប់ព្រំប្រទល់វៀតណាម។

**៧. គោលនយោបាយប្រឆាំងសាសនា ជនជាតិចាម និងជនជាតិវៀតណាម**

***គោលនយោបាយប្រឆាំងសាសនា*** ៖ ផ្អែកតាមសាក្សី **យ៉ុន គីម** គាត់បានសិក្សាពីគោលនយោបាយប្រឆាំងសាសនានៅក្នុងវគ្គរៀនសូត្រ គឺថា "បដិវត្តន៍មិនត្រូវធ្វើពីរដងទេ" មានន័យថា ការចាប់ផ្តើមចលនាបដិវត្តន៍ប្រជាជនមិនត្រូវមានជំនឿលើសាសនាទេ ដូចមានគំរូស្រាប់ នៅប្រទេសចិនមានហិង្សាវប្បធម៌សាសនាកើតឡើង (សាសនាត្រូវតែគម្ទេច និងលុបបំបាត់ចោលទាំងស្រុង)។

សាក្សីបានបន្តថា ក្រោយទទួលបានជ័យជំនះឆ្នាំ១៩៧៥ ព្រះសង្ឃនៅតែបន្តកាន់ព្រះពុទ្ធសាសនា។ នៅឆ្នាំ១៩៧៦ ប្រជាជននៅខេត្តក្រចេះឈប់គោរពព្រះពុទ្ធសាសនាដោយជំហរទៀតហើយ។ នៅខែកក្កដា ឬសីហា ឬចុងឆ្នាំ១៩៧៦ ព្រះសង្ឃមួយចំនួនត្រូវបានបញ្ជូនទៅស្រុកអូររាំងឪ ខេត្តកំពុងចាម ដូច្នេះ ពុំមានព្រះសង្ឃនៅសេសសល់ឡើយ "ការបញ្ចប់ព្រះពុទ្ធសាសនា គឺត្រូវតែគ្មានព្រះសង្ឃ"។ ទោះបីជា វត្តអារ៉ាមនៅមានរូបសណ្ឋានដើម ក៏វត្តទាំងនោះត្រូវបានប្រើប្រាស់នៅក្នុងគោលបំណងផ្សេង ៖ ដូចជា ឃ្លាំងដាក់សម្ភារៈ ឬក្លាយជាផ្ទះសម្បែង ឬជាកន្លែងផលិតឥដ្ឋជាដើម។ វត្តអារ៉ាមមួយត្រូវបានក្លាយជាកន្លែងប្រជុំរបស់បក្សកុម្មុយនិស្តកម្ពុជា និងវត្តអារ៉ាមមួយចំនួនទៀតបំលែងទៅជាមន្ទីរពេទ្យ។

***ការប្រព្រឹត្តទៅលើជនជាតិចាម[13]*** ៖ សាក្សី **យ៉ុន គីម** បានបដិសេធថា ទាក់ទងនឹងជនជាតិចាម មិនត្រូវបានលើកមកពិភាក្សានៅក្នុងវគ្គរៀនសូត្រទេ ដោយសារពួកគេក៏ចាត់ទុកជាជនជាតិខ្មែរដែរ ពុំមែនជាតិសាសន៍ដទៃ និងមិនបានចាត់ជា "ប្រជាជនថ្មី" ព្រមទាំងស្លៀកពាក់ខោអាវបក្សកុម្មុយនីស្តដូចប្រជាជនខ្មែរទូទៅ (អាវ

ខោពណ៌ខ្មៅ) និងតម្រូវឲ្យនិយាយភាសាខ្មែរនៅពេលធ្វើការ ប៉ុន្តែនៅផ្ទះពួកគេអាចនិយាយភាសាខ្លួនបាន។ ពួកគេរស់នៅក្នុងផ្ទះរួម។ ពិតប្រាកដណាស់ ជនជាតិចាមមួយចំនួនត្រូវបានបង្ខំឲ្យស៊ីសាច់ជ្រូក ឬអាហារតំណមដូចជា ប្រហុកជាដើម។ នៅក្នុងឃុំរបស់សាក្សី គាត់បានអនុញ្ញាតឲ្យជនជាតិចាមអាចប្រព្រឹត្តពិធីបូជាយញ្ញតាមបែបសាសនារបស់ពួកគេ។

***ការប្រព្រឹត្តទៅលើជនជាតិវៀតណាម*** ៖ សាក្សីពុំបានបញ្ជាក់ឲ្យបានជាក់លាក់ពីគោលនយោបាយបក្សពាក់ព័ន្ធនឹងជនជាតិវៀតណាមទេ ប៉ុន្តែជម្លោះរវាងប្រទេសទាំងពីរនៅតែបន្តកើតឡើងយ៉ាងក្ដៅគគុក បន្ទាប់ពីទទួលជ័យជំនះ ទាហានខ្មែរក្រហមបានសិក្សាពីយុទ្ធវិធីបង្ក្រាបជនជាតិវៀតណាម។ នៅមុនថ្ងៃ១៧ មេសា ១៩៧៥ ប្រជាជនវៀតណាមមួយភាគធំរស់នៅទឹកដីខេត្តក្រចេះ បានវិលត្រឡប់ទៅស្រុកកំណើតខ្លួនវិញ នៅពេលកងទ័ពវៀតណាមដកថយ ប៉ុន្តែចំពោះជោគវាសនារបស់ជនជាតិវៀតណាមដែលនៅសេសសល់ក្រោយឆ្នាំ១៩៧៥ ពុំត្រូវបានគេដឹងឡើយ។ សាក្សីស្គាល់ជនជាតិវៀតណាមពីរនាក់ ពួកគេរស់នៅស្រុកសំបូរ និងបានរៀបការជាមួយនារីជាជនជាតិខ្មែរ អ្នកទាំងពីរបន្តរស់នៅក្នុងសហគមន៍ដោយពុំមានបញ្ហា។

សំណួរពាក់ព័ន្ធនឹងយុវជនមកពីស្រុកមេម៉ត់ ដែលបញ្ជូនទៅការដ្ឋាន ប-៣ សាក្សីបានរៀបរាប់ថា យុវជនទាំងនោះប្រហែលជាជាប់សង្ស័យថា ជាអ្នកគាំទ្រវៀតណាម ព្រោះតំបន់របស់ពួកគេនៅកៀកជិតនឹងព្រំដែនវៀតណាម ដែលនេះអាចជាការដាក់ពិន័យ។

### ៨. ការបិទផ្សារ និងអាជីវកម្មនានា

សាក្សី **យ៉ុន គីម** បានផ្ដល់សក្ខីកម្មថា ផ្សារគឺនៅតែមានដំណើរការ ទោះបីជាក្រោយខ្មែរក្រហមចូលកាន់កាប់ខេត្តក្រចេះ។ សាក្សីមិនបានដឹងថា នៅពេលណាទីផ្សារត្រូវបានបិទ ប៉ុន្តែបានដឹងថា ក្រដាសប្រាក់ឈប់ចាយវាយនៅឆ្នាំ១៩៧៤។ ករណីនេះ "អាចសន្មតថា" ផ្សារ និងអាជីវកម្មនានាត្រូវបានបិទ ក្រោយពីក្រដាសប្រាក់លែងចរាចរ។ គោលនយោបាយបិទផ្សារ និងអាជីវកម្ម គឺមានចែងនៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ (សហព្រះរាជអាជ្ញាដាក់បង្ហាញដល់សាក្សី)។

### ៩. សក្ខីកម្មសាក្សី និងភាពគួរជឿជាក់បាន

សាក្សី **យ៉ុន គីម** មិនដូចជាសាក្សីមុនៗទេ សក្ខីកម្មរបស់គាត់ គឺមានភាពច្បាស់លាស់ និងប្រទាក់ប្រទងរវាងព្រឹត្តការណ៍ និងកាលបរិច្ឆេទ។ សាក្សីបានរាយនាមឈ្មោះមនុស្សជាច្រើនដែលត្រូវបានចាប់ខ្លួន និងមិនបានថ្លែងថា "គាត់ពុំមានការចងចាំ" ប៉ុន្តែចំណុចខ្លះ "គាត់មិនអាច" ឆ្លើយតបចំសំណួរ។ រឿងរ៉ាវដែល

បានរៀបរាប់ ភាគច្រើនជាចំណុចវិជ្ជមាន ក្នុងនាមជាសាក្សីនៅក្នុងព្រឹត្តការណ៍។ ទោះបីជា ជាដំណើររឿងមួយមានភាពខុសប្លែក ក៏សាក្សីហាក់សម្តែងនូវព័ត៌មានពិតប្រាកដនៃដំណើរជីវិតខ្លួននាសម័យនោះ។

### ខ. សក្ខីកម្មរបស់សាក្សី ខៀវ នៅ

សាក្សី **ខៀវ នៅ** កើតនៅភូមិត្រពាំងធំ[14] ស្រុកត្រាំកក់ ខេត្តតាកែវ។ សាក្សីបានបួសជាព្រះសង្ឃនៅវត្តត្រពាំងធំ តាំងពីវ័យក្មេង។ នៅវត្តត្រពាំងធំ គាត់បានជួប តា **ម៉ុក**[15] ដែលពេលនោះ តា **ម៉ុក** ក៏ជាព្រះសង្ឃផងដែរ ហើយក៏ជាអ្នកភូមិផងរបងជាមួយ។ នាពេលនោះ សាក្សីនៅក្មេងវ័យណាស់ ដូច្នេះ ទំនាក់ទំនងរវាងគាត់និង តា **ម៉ុក** ហាក់ដូចជា "កូនសិស្សលោក"។ តា **ម៉ុក** បានលាចាកសិក្ខាបទនៅដើមទសវត្សន៍ឆ្នាំ ១៩៤០ ចំណែករូបគាត់នៅបន្តជាព្រះសង្ឃនៅទសវត្សន៍ឆ្នាំ១៩៥០។ តា **ម៉ុក** បានទៅសួរសុខទុក្ខជាញឹកញាប់ និងសំណេះសំណាលជាមួយព្រះសង្ឃដទៃទៀតអំពីបញ្ហាទូទៅ ពួកគេបានពិភាក្សាពីទ្រឹស្តីកុម្មុយនីស្ត និងគោលការណ៍ព្រះពុទ្ធសាសនា[16] ពេលខ្លះ ពួកគេបានធ្វើស្រែចម្ការជាមួយគ្នាផងដែរ។ សាក្សី **ខៀវ នៅ** បានបួសជាព្រះសង្ឃរយៈពេលជាង ២៥វស្សា ហើយគាត់បានលាចាកសិក្ខាបទនៅក្រោយថ្ងៃ១៧ មេសា ១៩៧៥ "ក្រោយខ្មែរក្រហមទទួលជ័យជំនះ"។

នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តា **ម៉ុក** បានសុំសាក្សីឲ្យទៅធ្វើការជាមួយគាត់នៅភូមិភាគនីរតី។ ជាដំបូង សាក្សីកាន់ការងារទូទៅ បន្ទាប់មកក្លាយជាប្រធានមន្ទីរដឹកជញ្ជូនពាណិជ្ជកម្មនៅថ្នាក់ភូមិភាគ ដោយមើលការខុសត្រូវលើអ្នកបើកបរ និងសម្ភារៈដឹកជញ្ជូនពីឃ្លាំរដ្ឋទៅថ្នាក់ខេត្ត។

### ១. តួនាទីរបស់សាក្សីនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

សាក្សីបានរៀបរាប់ថា បន្ទាប់ពីលាចាកសិក្ខាបទ គាត់បានធ្វើដំណើរទៅស្រុកកំណើតខាងម្តាយ និងស្នាក់នៅមន្ទីរពេទ្យមួយរយៈ ដោយសារបញ្ហាសុខភាព។ នៅពេលជាស្រួលបួលឡើងវិញ តា **ម៉ុក** បានសុំឲ្យសាក្សីទៅធ្វើការជាមួយគាត់។

ជាដំបូង សាក្សីធ្វើការនៅជិតទន្លេកំពង់កន្ទួតនៅបន្ទាយទាហានចាស់របស់ **លន់ នល់** ។ តា **ម៉ុក** បានចាត់ឲ្យគាត់ធ្វើការជាអ្នក "រាប់លុយ" ប៉ុន្តែមិនទាន់ធ្វើផង ក្រដាស់ប្រាក់ក៏ឈប់ធ្វើចរាចរ និងផ្សារត្រូវបានបិត។ ដូចនេះ សាក្សីធ្វើការងារទូទៅជំនួសវិញ ដូចជា ឃ្វាលពពែ ធ្វើបញ្ជីសម្ភារៈ និងជួសជុលសម្ភារៈជាដើម។

ក្រោយមកទៀត សាក្សីត្រូវបានបញ្ជូនទៅមន្ទីរដឹកជញ្ជូនពាណិជ្ជកម្មនៅភូមិភាគនីរតី គាត់ធ្វើការនៅទីនោះរហូតដល់សម័យខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។ មន្ទីរនេះ គឺដឹកជញ្ជូនសម្ភារៈ ដូចជា ចានក្បាន

ស៊ីម៉ងស៍ ទៀន ឬសម្ភារៈនានា ពីឃ្លាំងរដ្ឋទៅខេត្ត និងដឹកត្រឡប់ពីខេត្តវិញនូវ កប្បាស ស្រូវ និង ដូង។ ការដឹកជញ្ជូនទំនិញ ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយសេដ្ឋកិច្ចតំបន់ និងចុះហត្ថលេខាពី **វន វ៉េត** ឬមន្ទីរ ក-២២។ នៅពេលចៅក្រម **ឡាវេន៍** ចោទសួរថាតើទំនិញនៅឃ្លាំងរដ្ឋមានដឹកជញ្ជូនទៅខេត្តកំពង់សោមឬទេ? សាក្សីបានឆ្លើយថា គាត់ទទួលខុសត្រូវតែភូមិភាគនីរតី ការដឹកជញ្ជូនទំនិញទៅកំពង់ផែ គឺស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋ។

### ២. រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង

តំណែងរបស់សាក្សីនៅមន្ទីរដឹកជញ្ជូនពាណិជ្ជកម្មភូមិភាគនីរតី ធ្វើឲ្យគាត់អាចរៀបរាប់បានពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រតិបត្តិការរវាងភូមិភាគនីរតី និងតំបន់សេចកិច្ចនារបបនោះ។

#### ក. ភូមិភាគនីរតី

ភូមិភាគនីរតីគ្រប់គ្រងដោយ តា **ម៉ុក** (លេខាភូមិភាគ) និង **សំ ប៊ិត** (ដែលជាអនុលេខាភូមិភាគ)។ សាក្សីបានបញ្ជាក់ថា គាត់ស្ថិតក្រោមបញ្ជាផ្ទាល់របស់ តា **ម៉ុក** ដោយសារគាត់ជាប្រធានមន្ទីរផ្នែកដឹកជញ្ជូនពាណិជ្ជកម្ម។ ភូមិភាគនីរតីមានខេត្ត ដូចជា ១.ខេត្តតាកែវ (**សោម** ជាប្រធាន) ២.ខេត្តកណ្តាល (**ជា** និង **ប្រាក់** ជាថ្នាក់ដឹកនាំ) ៣.ខេត្តកំពង់ចាម (**យុន** ជាប្រធាន) និង ៤.ខេត្តកំពង់ស្ពឺ (សាក្សីពុំចាំឈ្មោះ)។ អ្នកទាំងនេះបានឡើងទៅទីស្នាក់ការភូមិភាគនីរតីប្រចាំនៅទីក្រុងភ្នំពេញ នៅពេលពួកគេចូលរួមកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំ ក្នុងការទទួលយកគោលការណ៍ណែនាំ។ ឈ្មោះ **ជូ ជេត** ហៅ **ស៊ី** (លេខាភូមិភាគបស្ចិម) ក៏មកពីភូមិភាគនីរតីដែរ។ ស្រុកត្រាំកក់ (ស្រុក១០៥) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់១៣ (ខេត្តតាកែវ) ដែលដឹកនាំដោយ **ឆាយ** និង **គិត**។

#### ខ. តំបន់សេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ

សាក្សីបានឲ្យដឹងថា **វន វ៉េត** គឺជាអ្នកគ្រប់គ្រងកិច្ចការសេដ្ឋកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **ផេង អាន** គឺជាអ្នកគ្រប់គ្រងគណៈកម្មាធិការឧស្សាហកម្ម ឈ្មោះ **រឿង** គឺជាអ្នកគ្រប់គ្រងឃ្លាំងរដ្ឋ ចំណែកឯ **វ៉ាន់ រិទ្ធ** គឺមកពីមន្ទីរពាណិជ្ជកម្មបរទេស។ សាក្សីនៅតែរក្សាការសន្និដ្ឋានរបស់ខ្លួនធ្វើនៅតំណាក់កាលសហចៅក្រមស៊ើបអង្កេតថាលោក **ខៀវ សំផន** បានជំនួស **វន វ៉េត** នៅក្នុងផ្នែកពាណិជ្ជកម្មបរទេស នៅពេល **វន វ៉េត** "បាត់ខ្លួន"[17]។ ទំនាក់ទំនងរវាងសាក្សី និងលោក **ខៀវ សំផន** ព្រោះតែលោក **ខៀវ សំផន** ជាអ្នកមានអំណាចសម្រេចអនុញ្ញាតឲ្យបញ្ជូនសម្ភារៈចេញ។

### ៣. ទំនាក់ទំនងជាមួយថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ

ទោះបីជាសាក្សីពុំមានមុខងារធំដុំ ក៏គាត់អាចទំនាក់ទំនងជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើន។ ទំនាក់ទំនងជាញឹកញាប់ គឺជាមួយភូមិភាគនិរតី **(តាម៉ុក)**។ សាក្សីបានជួប **ប៉ុល ពត** ម្តងនៅផ្ទះ **តាម៉ុក** នៅខេត្តតាកែវ។

សាក្សីបានជួបលោក **ខៀវ សំផន** ពីរដង គឺនៅពេលគាត់បានអមដំណើរប្រជាជនពីចំការកៅស៊ូឡើងមកជួបជនជាប់ចោទ កិច្ចប្រជុំនេះរៀបចំនៅមន្ទីរពាណិជ្ជកម្មបរទេស ដែលពួកគេបានពិភាក្សាអំពីក្រណាត់តម្បាញនៅខេត្តបាត់ដំបង និងឧបករណ៍ប្រើប្រាស់ (ជំនួសរោងចក្រ) និងការប្រើសំបកដបដែលប្រើប្រាស់រួចសម្រាប់ដាក់ទឹកត្រី។ ជំនួបទី២ ក៏នៅកន្លែងដដែល នៅពេលប្រជាជនខេត្តកណ្តាលបានស្នើសុំឲ្យគាត់ជួយទាក់ទងថ្នាក់លើអំពីបញ្ហាផ្លូវត្រូវបំផ្លាញដោយទឹកជំនន់។ នាពេលនោះ សាក្សីបានទាក់ទងលោក **ខៀវ សំផន** ដោយសារក្អួយប្រសាររបស់គាត់ជាជំនិតរបស់ជនជាប់ចោទ។ នៅពេលជួបលោក **ខៀវ សំផន** គាត់ពុំដែលឃើញវត្តមានរបស់ **វន វ៉េត** ទេ។

ចំពោះលោក **នួន ជា** សាក្សីបានជួបគាត់ម្តងគត់នៅដើមឆ្នាំ១៩៧៨។ លោក **នួន ជា** បានកាក់ឡានគាត់ឲ្យឈប់ និងបានឲ្យគាត់ស្វែងរកឧបករណ៍តន្ត្រីបុរាណនៅឃ្លាំងរដ្ឋ ហើយឲ្យផ្ញើទៅស្ថានីយវិទ្យុ។

### ៤. គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ

ព័ត៌មានពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ - សហករណ៍ - និងការចាប់ខ្លួន សាក្សីអាចផ្តល់បានតិចតួចបំផុត ប៉ុន្តែបានពិពណ៌នាពីមង្គលការរបស់គាត់ និងស្រ្តីមកពីមន្ទីរដេរប៉ាក់។

#### ក. ការជម្លៀសដោយបង្ខំ

សាក្សី **ខៀវ នៅ** បានឲ្យដឹងថា គាត់មិនបានឃើញដោយផ្ទាល់ភ្នែកពីការជម្លៀសប្រជាជនទេ គឺបានដឹងនៅពេលប្រជាជនមកដល់តំបន់របស់គាត់។ សាក្សីបានរៀបរាប់ថា ៖

> *ប្រជាជនរាប់ពាន់នាក់ត្រូវបានជម្លៀស អ្នកអាចឃើញហ្វូងមនុស្សនៅគ្រប់ទិសទី។ ខ្ញុំស្គាល់ប្រជាជន និងសាច់ញាតិមួយចំនួនរស់នៅភ្នំពេញ និងតាកែវ។ ខ្ញុំបានទៅជួបពួកគាត់ និងបានសួរនាំពីបញ្ហានេះ ទើបបានដឹងថា នេះជាការជម្លៀសប្រជាជន។*

សាក្សីបន្តថា ប្រជាជនជម្លៀសអាចទៅទីកន្លែងដែលខ្លួនប្រាថ្នា ភាគច្រើនពួកគេត្រឡប់ទៅស្រុកកំណើតវិញ។ ព្រះសង្ឃក៏ត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ និងខេត្តតាកែវដែរ ពួកគេបានមកជួបជុំគ្នានៅវត្តអង្គរកា។

**ខ. សហករណ៍ និងការដ្ឋាន**

ភូមិនិងសហករណ៍ថ្មីៗត្រូវបានបង្កើតឡើង ដោយសារតែលំហូរចូលនៃប្រជាជនថ្មីច្រើនហួសហេតុពេក។ ប្រជាជនទាំងអស់រស់នៅក្នុងសហករណ៍ លើកលែងតែអ្នកមកពីក្រសួងស្ថាប័ន និងប្រធានមន្ទីរ។ នៅក្នុងសហករណ៍ ពួកគេតម្រូវឲ្យធ្វើកសិកម្ម "តាមទម្លាប់ចាស់ ប៉ុន្តែមានលក្ខណៈជាសមូហភាព"។ "ការងារទាំងនោះ រួមមាន សាងសង់ទំនប់ទឹក ជីកប្រឡាយ និងបរិភោគរួម"។ សាក្សីមិនបានដឹងពីលក្ខខណ្ឌរស់នៅរបស់ប្រជាជនច្បាស់លាស់ទេ ដោយសារគាត់រស់នៅតំបន់នោះរយៈពេលខ្លី "គាត់ត្រូវបានចាត់តាំងឲ្យធ្វើការងារថ្មី"។

**គ. ការចាប់ខ្លួន និងការបាត់ខ្លួន**

សាក្សី **ខៀវ នៅ** បានបញ្ជាក់សហព្រះរាជអាជ្ញាថា ការបាត់ខ្លួននៅសម័យនោះ គឺកើតឡើងជាញឹកញាប់ ប៉ុន្តែមិនដឹងពីមូលហេតុ សាក្សីឮថា អ្នកបាត់ខ្លួនទាំងនោះត្រូវបានចោទប្រកាន់ថាជាជនក្បត់។ សាក្សីបានឮពីការបាត់ខ្លួនរបស់ **វន វេត** និងសមមិត្តពីររូបទៀត **ហ៊ូ នឹម** និង **ហ៊ូ យ៉ុន**។ តំណាងសហព្រះរាជអាជ្ញាលោក **លីសាក់** បានសួរបញ្ជាក់អំពី **ជូ ជេត** សាក្សីបានឮពីការបាត់ខ្លួនរបស់ថ្នាក់ដឹកនាំនៅភូមិភាគបស្ចិមប៉ុន្តែមិនបានដឹងពីជោគវាសនាភរិយារបស់ **ជូ ជេត**។[18]

**ឃ. វគ្គរៀនសូត្រ និងកិច្ចប្រជុំស្វ័យទស្សន៍** 

សាក្សីបានផ្តល់សាក្ខីកម្មថា ប្រជាជនត្រូវចូលរួមវគ្គសិក្សា ដូចជា អំពីលក្ខខណ្ឌរស់នៅជាដើម។ កិច្ចប្រជុំទិតៀនន គឺជាវគ្គមួយដែលប្រជាជនអាចពិភាក្សាអំពីដំណើរវិវត្តន៍របស់បុគ្គលម្នាក់ៗ និងអំពីកំហុស ដែលបណ្តាលឲ្យមិនសម្រេចតាមផែនការ។ វគ្គរៀនសូត្ររៀបចំនៅភូមិភាគនិរតី ក្រោមអធិបតីរបស់អនុលេខាភូមិភាគ **សំ ប៊ិត** ជាទូទៅ ពាក់ព័ន្ធនឹងមាគ៌ាបដិវត្តន៍ ដូចជា របៀបនៃការធ្វើកសិកម្ម និងការដាក់ការងារ ព្រោះប្រជាជនជាង ៨៥% គឺជាកសិករ។

**ង. មង្គលការដោយការផ្សំផ្គុំ**

សាក្សី **ខៀវ នៅ** បានឲ្យដឹងថា ការប្រារព្ធពិធីតាមបែបសាសនាពុំត្រូវបានរៀបចំទេនៅក្នុងមង្គលការនាសម័យនោះ។ កាលបើមេឃុំអនុញ្ញាតឲ្យមានរៀបពិធីមង្គលការដល់កូនកម្លោះនិងកូនក្រមុំ មេក្រុមនីមួយៗ

ត្រូវចាត់ចែងឲ្យមានពិធីនេះភ្លាម។ ពិធីមង្គលការត្រូវបានរៀបចំឡើងខុសៗគ្នា ទៅតាមក្រុម ឬភូមិ ឬឃុំនីមួយៗ។ សាក្សីបានឲ្យដឹងថា តា **ម៉ុក** បានរៀបចំមង្គលការឲ្យគាត់។ សំណួរថាតើភរិយារបស់គាត់ធ្លាប់ស្គាល់គាត់ឬទេ? សាក្សីឆ្លើយថា ភរិយារបស់គាត់ធ្លាប់ស្គាល់គាត់ ប៉ុន្តែមិនសូវច្បាស់ទេ ហើយយើងបានដឹងជាមុនពីការរៀបចំមង្គលការនេះ។ សាក្សីរៀបរាប់ថា ពួកគាត់បានជួបគ្នា និងញញឹមដាក់គ្នានៅក្នុងពិធីចុះបញ្ជីអាពាហ៍ពិពាហ៍។ នៅក្នុងពិធីមង្គលការ ពុំមានវត្តមានញាត្តិមិត្ត មានតែសមាជិកខ្មែរក្រហមប៉ុណ្ណោះ។

### ច. ការបោះបង់សាសនាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ

នៅមុនថ្ងៃទី១៧ មេសា ១៩៧៥ សាក្សីបានរៀបរាប់ថា "អង្គការ" (តាមរយៈកងឈ្លប) បានបញ្ជាគាត់ឲ្យប្តូរពីវត្តត្រពាំងធំទៅវត្តអង្គរ។ នៅទីនោះ គាត់បានជួបព្រះសង្ឃជាច្រើនដែលមកពីតំបន់ផ្សេងៗគ្នា។ ព្រះសង្ឃទាំងនោះត្រូវបានស្នើសុំឲ្យលាចាកសិក្ខាបទ ពុំមានព្រះសង្ឃណាម្នាក់ហ៊ានបដិសេធទេ[19]។ ទោះបីជាយ៉ាងណា លាចាកសិក្ខាបទគឺដើម្បីឲ្យបានរស់រានមានជីវិត។[20] "ព្រះសង្ឃលាចាកសិក្ខាបទ ដោយស្ម័គ្រចិត្ត ដោយពុំមានការចាប់ ឬបង្ខំទេ"។ នៅពេលលាចាកសិក្ខាបទ គឺមានរៀបចំពិធីសាសនាផងដែរ។

នៅក្នុងសេចក្តីថ្លែងការណ៍ចំពោះមុខសហចៅក្រមស៊ើបអង្កេត សាក្សីបានថ្លែងថា គាត់បានដឹងពីគម្រោងផ្សឹកព្រះសង្ឃ មុនពេលសកម្មភាពនេះបានកើតឡើង តាមរយៈការអានទស្សនាវដ្តី និងការជួបសន្ទនាជាមួយសមាជិកក្រុមឥស្សរៈ។ ទោះបីជាបានលាចាកសិក្ខាបទហើយក៏ដោយ សាក្សី **ខៀវ នៅ** នៅតែបានបន្តកាន់ព្រះពុទ្ធសាសនាដោយស្ងៀមស្ងាត់។ នៅពេលសួរថា ហេតុអ្វីបានជាគាត់មិនអាចធ្វើដោយបើកចំហរ? សាក្សីឆ្លើយថា "តើកាន់សាសនាដោយរបៀបណា បើអត់មានព្រះសង្ឃផង"។ នាពេលបច្ចុប្បន្ន គាត់ពុំមានចំណាប់អារម្មណ៍ត្រឡប់ទៅជាព្រះសង្ឃវិញទេ ព្រោះគាត់មានគ្រួសារដែលត្រូវមើលថែ។

## III. **និដ្ឋភាពផ្នែកច្បាប់ និងនីតិវិធី**

សប្តាហ៍នេះ បានលេចឡើងពីតម្រូវការនៃការណែនាំបន្ថែម អំពីការប្រើប្រាស់សេចក្តីថ្លែងការណ៍សាក្សីធ្វើតំណាក់កាលសហចៅក្រមស៊ើបអង្កេត ជាផ្នែកមួយនៃសក្ខីកម្មនៅក្នុងតុលាការ។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីលោក **នួន ជា** អាចប្រើប្រាស់ឯកសារមួយចំនួន ក្នុងគោលបំណងសួរផ្ទុញ

សាក្សី។ ជាចុងក្រោយ អង្គជំនុំជម្រះបានចេញសេចក្ដីព្រមានជាផ្លូវការណ៍ចំពោះក្រុមមេធាវីការពារក្ដីលោក **នួន ជា** ដោយបានប្រព្រឹត្តកំហុសវិជ្ជាជីវៈ។

### ក. សេចក្ដីថ្លែងការណ៍ធ្វើចំពោះសហចៅក្រមស៊ើបអង្កេត ចាត់ទុកថា ជាផ្នែកមួយនៃសក្ខីកម្ម

ដើម្បីជាប្រយោជន៍នៃការជម្រុញកិច្ចដំណើរការសវនាការឲ្យកាន់តែលឿនទៅមុខ អង្គជំនុំជម្រះបានទទួលយកទម្រង់ខាងក្រោមក្នុងការសួរដេញដោលសាក្សី។ សេចក្ដីសង្ខេបនៃសេចក្ដីណែនាំចុះកាលបរិច្ឆេទថ្ងៃទី១៣ មិថុនា ២០១២[21] ៖

> *...នៅពេលចាប់ផ្ដើមសួរដេញដោលសាក្សីទីមួយៗ ភាគីត្រូវសួរសាក្សីថាតើសាក្សីធ្លាប់ស្គាល់សេចក្ដីថ្លែងការណ៍ ដែលពួកគេធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងថាតើសេចក្ដីថ្លែងការណ៍នេះបង្ហាញនូវតថភាពត្រឹមត្រូវឬទេ? នៅ<u>ពេលសាក្សីបង្ហាញថា គាត់ចងចាំនូវសេចក្ដីថ្លែងការណ៍ និងដំណើររឿងត្រូវបានកត់ត្រាបានយ៉ាងត្រឹមត្រូវដោយសហចៅក្រមស៊ើបអង្កេត ភាគីពុំចាំបាច់សុំឲ្យសាក្សីបញ្ជាក់សារជាថ្មីទេ បើមិនដូច្នោះ នាំឲ្យបង្ខំឲ្យសាក្សីលើកឡើងនូវសេចក្ដីថ្លែងការណ៍ដដែលៗ</u>។ ភាគីគួរតែយកចិត្តទុកដាក់លើ បញ្ហាសំខាន់ផ្សេងទៀត (តួយ៉ាង៖ បញ្ហាទាំងឡាយដែលពុំមាននៅក្នុងសេចក្ដីថ្លែងការណ៍) ឬក៏ការលើកយកបញ្ហាប្រឈមពាក់ព័ន្ធនឹងភាពអាចជឿទុកចិត្ត បាននៃសេចក្ដីថ្លែងការណ៍ ឬសក្ខីកម្មរបស់សាក្សី។ (មើលការពន្យល់នូវចំណុចដែលបានគូសបន្ទាត់ពីក្រោម)។*[22]

ជាលទ្ធផល ប្រសិនបើសាក្សីបញ្ជាក់នៅចំពោះមុខតុលាការពីសច្ចភាពនៃសេចក្ដីថ្លែងការណ៍ធ្វើចំពោះមុខសហចៅក្រមស៊ើបអង្កេត ករណីនេះត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ចំណុចនេះមិនចាំបាច់សួរដេញដោលសារឡើងវិញទេ។ ទោះបីជា ចំណុចនេះបានជួយពន្លឿនកិច្ចដំណើរការនីតិវិធី ក៏ករណីនេះបានបង្កជាផលវិបាកមួយចំនួន។ ភាគីដែលមានបំណងសួរដេញដោលសាក្សីទៅលើទិដ្ឋភាពជាក់លាក់នៃចម្លើយដែលបានផ្ដល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ត្រូវជួបបញ្ហាប្រឈមដោយអង្គជំនុំជម្រះបានហាមប្រាមមិនឲ្យសួរឡើងវិញ។

តម្រូវការឲ្យមានការណែនាំឲ្យច្បាស់លាស់ គឺបានលេចឡើងកាលពីរសៀលថ្ងៃពុធ នៅពេលចាប់ផ្ដើមសួរដេញដោលសាក្សី **ខៀវ នៅ** ដោយភាគីសហព្រះរាជអាជ្ញា។ មេធាវី **វែកកែន** បានជំទាស់នឹងវិធីសាស្ត្ររបស់តំណាងសហព្រះរាជអាជ្ញា **វ៉េង ហ៊ត់** ចាប់ផ្ដើមសំណួរដោយលើកយកអង្គហេតុ ដែលសាក្សីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ មេធាវីបានបន្តថា នៅពេលលើកពីអង្គហេតុ "គឺចាំបាច់ត្រូវសួរសំណួរបើក ជាជាងអានឯកសាររំឭកការចងចាំទៅសាក្សី"។ ជាការឆ្លើយតប ចៅក្រម **ឡាវែន៍** បានពន្យល់ថា៖

*ករណីនេះពុំចាំបាច់ចោទសំណួរតាំងពីដើមទេ គឺថា យើងត្រូវសួរសំណួរបន្ថែមតែប៉ុណ្ណោះ ដែលការសង្ខេបនៃសេចក្ដីថ្លែងការណ៍មុន គឺពុំមែនជារឿងខុសប្លែកទេ! ចំណុចគួរកត់សម្គាល់ គឺថា ប្រសិនបើសាក្សីមិនឯកភាពទៅនឹងរបៀបនៃការសួរសំណួរ ឬសំណួរមានលក្ខណៈជាការរំឭក សាក្សីនឹងសម្ដែងឲ្យយើងដឹង។*[23]

តាមទស្សនៈរបស់សាធារណជន គឺថា ការលើកពីព័ត៌មានសារជាថ្មីមានដែលធ្វើនៅចំពោះសហចៅក្រមស៊ើបអង្កេតមុនការសួរសំណួរ គឺពិតជាបានផ្ដល់នូវបរិបទ និងបង្ហាញពីសក្ខីកម្មរបស់សាក្សីដល់សាធារណជនទូទៅ ដែលប្រការនេះជាចំណុចគួរឲ្យអបអរសាទរ តែបើមិនធ្វើដូច្នេះទេ សេចក្ដីថ្លែងការណ៍របស់សាក្សីចំពោះមុខសហចៅក្រមស៊ើបអង្កេតនឹងមិនត្រូវបានឮនៅក្នុងតុលាការ ហើយក៏លេចឡើងនូវភាពមិនច្បាស់ ថាតើបានផ្ដល់មូលដ្ឋានគ្រប់គ្រាន់នៅក្នុងការសួរសាក្សី? កត្តានេះនាំឲ្យមានការព្រួយបារម្ភថា វិធីសាស្ត្រថ្មីដែលអង្គជំនុំជម្រះ ទើបតែសម្រេចយក អាចនឹងធ្វើឲ្យសាធារណជនមានការលំបាក ជាពិសេសក្នុងការទទួលបានព័ត៌មានពេញលេញចំពោះសក្ខីកម្មរបស់សាក្សី លុះត្រាតែ របាយការណ៍របស់សហចៅក្រមស៊ើបអង្កេត ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

លើសពីនេះទៀត នៅក្នុងករណីសាក្សីបានបដិសេធលើចំណុចមួយចំនួន ឬទាំងស្រុងលើសេចក្ដីថ្លែងការណ៍ ហេតុផលពុំត្រូវបានឲ្យដឹងឡើយ។ ***<u>គួរកត់សម្គាល់ថា</u>*** នៅពេលអង្គជំនុំជម្រះបានសួរដេញដោលសាក្សី **ខៀវ នៅ** ឲ្យបញ្ជាក់ថា សាក្សីបានអានកិច្ចសម្ភាសន៍របស់ខ្លួន "បាទ! ប៉ុន្តែចំណុចខ្លះ គឺវាមិនត្រឹមត្រូវទាំងស្រុងនោះទេ ព្រោះខ្ញុំត្រូវការ... ខ្ញុំគិតថា វាមិនត្រឹមត្រូវទេ"។ គួរឲ្យសោកស្ដាយ អង្គជំនុំជម្រះមិនបាន

បញ្ជាក់ ឬរកដំណោះស្រាយចំពោះបញ្ហានេះ។ ផ្ទុយទៅវិញ តុលាការបែរជាផ្លាស់ប្តូរ សំណួរដោយសួរសាក្សីថា "ជាទូទៅ" សេចក្តីថ្លែងការណ៍ដែលបានអាន គឺមានភាពស៊ីសង្វាក់គ្នា។ ជាលទ្ធផល ផ្នែកខ្លះនៃរបាយ-ការណ៍នៅសហចៅក្រមស៊ើបអង្កេត ដែលសាក្សីបានបដិសេធ ចំណុចនេះមិនត្រូវបានបញ្ជាក់ឡើយនៅក្នុងសក្ខីកម្មទាំងមូល។[24]

**ខ. ភាពអាចជឿទុកចិត្តបាននៃរបាយការណ៍នៅតំណាក់កាលសហចៅក្រមស៊ើបអង្កេត**

ចំពោះសេចក្តីសម្រេចថ្មី ដែលសំដៅថា សេចក្តីថ្លែងការណ៍នៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត គឺជាផ្នែកមួយនៃសក្ខីកម្មដោយផ្ទាល់របស់សាក្សី ដូច្នេះ កាលពីរសៀលថ្ងៃព្រហស្បតិ៍ ភាពត្រឹមត្រូវ និង ភាពអាចជឿទុកចិត្តបាននៃសេចក្តីថ្លែងការណ៍ត្រូវបានចោទជាចំណោទដោយក្រុមមេធាវីការពារក្តី។

មេធាវី **វែកគែន** បានទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះ ចំពោះភាពមិនស្របគ្នារវាងខ្សែអាត់សម្លេង និងកំណត់ហេតុស្តាប់ចម្លើយសាក្សី **ខៀវ នៅ** ដោយលើកថា ពាក្យដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ គឺមិនមាននៅក្នុងខ្សែអាត់សម្លេងទេ ដូចជា ពាក្យ "កា.ហ្សេ.បេ និង ស៊ី.អាយ.អេ ជាដើម"[25]។ លោកមេធាវីបានថ្លែងថា ដើម្បីជាភាពច្បាស់លាស់ គាត់បានស្នើសុំឲ្យអង្គភាពផ្នែកកិច្ចការប្រតិចារិកចម្លងខ្សែអាត់សម្លេងឡើងវិញ។ ជាការឆ្លើយតប អង្គជំនុំជម្រះបានចង្អុលបង្ហាញថា គឺពុំមានភាពផ្ទុយគ្នានៃភស្តុតាងទាំងពីរ និងពុំបាច់ការស្នើសុំបន្ថែមទេ [26]។

នៅចុងបញ្ចប់នៃសវនាការនាថ្ងៃនោះ មេធាវី **ផេស្តមិន** បានលើកបញ្ហានេះម្តងទៀត ដោយថ្លែង ថា នៅពេលគាត់ធ្វើការប្រៀបធៀបប្រហែលជា ៤ទំព័រ រវាងប្រតិចារិកនៃបទសម្ភាសន៍ - សេចក្តីសង្ខេបនៅក្នុងសំណុំរឿង - និងកំណត់ហេតុជាលាយលក្ខអក្សរនៃបទសម្ភាសន៍។ គាត់មានការ "ភ្ញាក់ផ្អើលជាខ្លាំង!" ថា ៖

> *វាដូចជាការសន្ទនារវាងអ្នកស៊ើបអង្កេត និងសាក្សី។ វាមានភាពរញ៉េរញ៉ៃ និងច្របូកច្របល់ណាស់ វាមិនអាចឆ្លុះបញ្ចាំងថា ព័ត៌មាននោះទទួលបានពីសាក្សី និងព័ត៌មានណាខ្លះ ដែលបានផ្តល់ឲ្យសាក្សី។ ចំណែកឯបញ្ហាផ្សេងទៀត គឺថា សេចក្តីសង្ខេប... គឺមិនត្រឹមត្រូវ និងអាចមានការភ័ន្តច្រលំ។ វាគឺមិនមែនជាសេក្តីសង្ខេបទេ ប៉ុន្តែជាការបកស្រាយផ្ទាល់ខ្លួនទៅវិញ។ នេះជាអ្វីដែលខ្ញុំបានធ្វើការប្រៀបធៀបតែ ៤ទំព័រដំបូង។*

ដូច្នេះ មេធាវី **ផេស្គមិន** បានស្នើសុំថា សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ គឺមិនមានភាពគួរឲ្យជឿជាក់បានទេ ហើយអង្គជំនុំជម្រះក៏មិនគួរផ្តល់ទម្ងន់ឲ្យដែរ។ តំណាងសហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានច្រានចោលសំណើនេះ និងបានចង្អុលបង្ហាញថា សក្ខីកម្មរបស់សាក្សី គឺជាទូទៅមាន "ភាពស៊ីសង្វាក់គ្នា" ជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងបញ្ជាក់ពីភាពត្រឹមត្រូវ។

អង្គជំនុំជម្រះពុំបានចេញសេចក្តីសម្រេច ឬធ្វើសេចក្តីអត្ថាធិប្បាយលើបញ្ហានេះឡើយ។ ទោះបីជាវិធានផ្ទៃក្នុងមិនតម្រូវឲ្យអង្គជំនុំជម្រះបង្ហាញពីភាពជឿជាក់នៃភស្តុតាងនីមួយៗ សេចក្តីសម្រេចលើបញ្ហា នេះនឹងអាចបញ្ជាក់ពីស្តង់ដារចំពោះការទទួលយកភស្តុតាង មានចែងនៅក្នុងវិធាន ៧៨(៣) ដែលបានអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចបដិសេធនូវភស្តុតាង ប្រសិនណាមិនមានភាពគួរឲ្យជឿជាក់ ដូច្នេះ "អង្គហេតុដែលមិនអាចទទួលយកបាន គឺជាចំណុចដែលត្រូវបញ្ជាក់"។

### គ. ការធានាយុត្តិធម៌ មិនពិចារណាភស្តុតាងយោងតាមវិធាន៨៧ ប៉ុន្តែអាចប្រើប្រាស់សួរដេញដោលសាក្សី

មេធាវី **អេនឌ្រូ អ៊ីនូហ្ស៊ី** ជាមេធាវីការពារក្តីជនជាប់ចោទ **នួន ជា** បានជូនដំណឹងតុលាការ កាលពីព្រឹកថ្ងៃអង្គារថា ក្រុមរបស់ពួកគេបានដាក់សំណើសុំឲ្យទទួលយកដីកាមួយរបស់សហចៅក្រមស៊ើបអង្កេតថា ជាភស្តុតាងថ្មី ដោយសំអាងលើវិធាន ៨៧(៤) ក្នុងគោលបំណងសួរផ្ទៀងសាក្សី **យុន គីម**[27]។ កាលពីថ្ងៃពុធ មុនពេលក្រុមមេធាវីការពារក្តីលោក **នួន ជា** ចាប់ផ្តើមសួរដេញដោលសាក្សី **យុន គីម** មេធាវី **អ៊ីនូហ្ស៊ី** បានសួរបញ្ជាក់ពីសំណើរបស់ពួកគេ។ ជាការឆ្លើយតប ប្រធានអង្គជំនុំជម្រះបានថ្លែងថា ឯកសារតុលាការនានា ដូចជា ដីការបស់សហចៅក្រមស៊ើបអង្កេត[28] គឺមិនចាត់ទុកថាជា "ភស្តុតាង" ទេ និងមិនស្ថិតនៅក្នុងវិធាន៨៧ដែរ។ អង្គជំនុំជម្រះបានកំណត់សេចក្តីថា មិនមានតម្រូវការណាមួយសម្រាប់ក្រុមមេធាវីការពារក្តីលោក **នួន ជា** ដាក់សំណើសុំឲ្យទទួលយកឯកសារតុលាការ ថាជាភស្តុតាងថ្មី ប៉ុន្តែបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារនោះនៅក្នុងការសួរដេញដោលសាក្សី។[29]

គួរឲ្យភ្ញាក់ផ្អើល! មេធាវី **អ៊ីនូហ្ស៊ី** បែរជាបដិសេធឱកាសប្រើប្រាស់ឯកសារនោះវិញ ដោយលើកឡើងពីភាពខុសគ្នានៃមូលហេតុដែលក្រុមខ្លួនទាមទារ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ លោកមេធាវីបានទទូចថា ពួកគេនៅតែរក្សាជំហរថា ឯកសារសួរផ្ទៀងផ្ទាត់អាចមិនមែនជាភស្តុតាង ប៉ុន្តែឯកសារតុលាការត្រូវតែជាភស្តុតាង គឺថា "ដីកាអាចមានកំណត់អង្គហេតុ ហើយអង្គហេតុនោះអាចជាភស្តុតាង"។

### ឃ. ឯកសារមិនមាននៅក្នុងបញ្ជីឯកសារ មិនអាចប្រើប្រាស់សួរដេញដោលសាក្សី

ក្រុមមេធាវីការពារក្តីលោក **នួន ជា** បានស្នើសុំស្រដៀងគ្នាដែរ គឺការទទួលយកឯកសារពីរច្បាប់ក្នុងគោលបំណងសួរផ្ទៀងផ្ទាត់សាក្សី **ខៀវ នៅ**[30]។ នៅពេលដល់វេទិកាសួរដេញដោលសាក្សី មេធាវី **ផេស្តមិន** បានសុំការបញ្ជាក់ពីអង្គជំនុំជម្រះ ចំពោះពាក្យសុំរបស់ខ្លួន។ ឯកសារ ១ច្បាប់ មាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ប៉ុន្តែ ១ច្បាប់ទៀត មិនមាននៅក្នុងបញ្ជីតុលាការទេ។[31] ជំនួសមុខឲ្យប្រធានអង្គជំនុំជម្រះលោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បានថ្លែងបញ្ជាក់ថា មេធាវី **ផេស្តមិន** អាចប្រើប្រាស់ឯកសារ ដែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា ប៉ុន្តែបានច្រានចោលឯកសារដែលមិនមាននៅក្នុងបញ្ជី។ មេធាវី **ផេស្តមិន** បានសម្រេចបដិសេធមិនប្រើឱកាសខ្លួនក្នុងការសួរដេញដោលសាក្សី ដូចដែលមេធាវី **អ៊ីនូហ្ស៊ី** បានធ្វើឡើងមុននេះ។ មេធាវី **ផេស្តមិន** បានលើកសំអាងថា វាសំខាន់ណាស់ក្នុងការប្រើប្រាស់ឯកសារទាំងពីរច្បាប់ ព្រោះឯកសារទាំងពីរយោងគ្នាទៅវិញទៅមក និងមានព័ត៌មានដោះបន្ទុកយ៉ាងសំខាន់ ប៉ុន្តែពួកគេត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់។

### ង. ការប្រើប្រាស់សេចក្តីថ្លែងការណ៍សាក្សីដែលមិនទាន់មកផ្តល់សក្ខីកម្ម

អំឡុងពេលនៃការសួរដេញដោលសាក្សី **យុន គីម** កាលពីថ្ងៃ ទី២០ មិថុនា លោកចៅក្រម **ឡាវែន៍** បានដាក់បង្ហាញសេចក្តីថ្លែងការណ៍របស់បុគ្គលពីររូប និងសុំឲ្យសាក្សីផ្តល់យោបល់ (សូមមើលត្រង់ចំណុចខាងលើ II.ក.១)។ មេធាវី **អ៊ីនូហ្ស៊ី** បានធ្វើអន្តរាគមន៍ទាំងពីរលើក និងសុំការបញ្ជាក់ថាតើបុគ្គលទាំងពីររូបមានឈ្មោះនៅក្នុងបញ្ជីសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មឬទេ? តំណាងសហព្រះរាជអាជ្ញា **លីសាក់** បានចង្អុលបង្ហាញថា កាលពីសប្តាហ៍មុន ក្រុមមេធាវីការពារក្តីលោក **នួន ជា** បានស្នើសុំប្រើប្រាស់សេចក្តីថ្លែងការណ៍របស់សាក្សី ដែលនឹងគ្រោងឡើងមកបង្ហាញខ្លួននៅក្នុងតុលាការ នៅក្នុងលក្ខខណ្ឌថា ឈ្មោះសាក្សីនឹង

មិនត្រូវបង្ហាញ[32]។ ដូច្នេះ អង្គជំនុំជម្រះបានកែសម្រួលសេចក្តីសម្រេច គឺអនុញ្ញាតតាមការស្នើសុំរបស់ក្រុមមេធាវីការពារក្តីលោក **នួន ជា**។

សេចក្តីសម្រេចថ្មី នឹងមានផលប្រយោជន៍ដល់ភាគីទាំងអស់ ក្នុងការស្វែងរកការពិតពីសាក្សី ដ៏រាបណា អត្តសញ្ញាណរបស់សាក្សីដែលនឹងមកផ្តល់សក្ខីកម្មនាពេលអនាគតត្រូវបានការពារ[33] អ្នកអង្កេតការជាច្រើន សង្ឃឹមថា ការបោះជំហានទៅមុខតាមរយៈការវិវត្តន៍នៃការបកស្រាយលើវិធានភស្តុតាងកាន់តែកើនជាលំដាប់។

### ច. តម្រូវការជូនដំណឹងជាមុនស្តីពីការប្រើប្រាស់ឯកសារ

ពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារក្នុងការសួរដេញដោលសាក្សី មេធាវី **វែកគិន** បានស្នើសុំថា ក្រុមប្រឹក្សាអង្គជំនុំជម្រះ គួរជូនដំណឹងដល់ភាគីពីគោលបំណងប្រើប្រាស់ឯកសារ យ៉ាងតិច ១ថ្ងៃ ជាមុន ដូច្នេះភាគីអាចនឹងត្រៀមរៀបចំឲ្យបានទាន់ពេលវេលា។ ជាការឆ្លើយតប ចៅក្រម **ឡាវែន៍** បានបញ្ជាក់ថា "ទំនួលខុសត្រូវ និងកាតព្វកិច្ចនានា គឺជារបស់ភាគីមិនមែនជារបស់ចៅក្រមនោះទេ"។ ដូច្នេះ ការតម្រូវឲ្យភាគីជូនដំណឹងជាមុនដល់តុលាការក្នុងការប្រើប្រាស់ឯកសារ ក៏តម្រូវការនេះ មិនធ្លាក់មកជាបន្ទុករបស់ក្រុមប្រឹក្សាជំនុំជម្រះទេ។

### ឆ. ការអនុញ្ញាតឲ្យជនជាប់ចោទសួរសំណួរទៅសាក្សី ប៉ុន្តែមិនឲ្យធ្វើសេចក្តីថ្លែងការណ៍

កាលពីថ្ងៃពុធ កំឡុងពេលក្រុមមេធាវីការពារក្តីលោក **នួន ជា** សួរដេញដោលសាក្សី **យុន គីម** មេធាវី **អ៊ីនូហ្សុី** បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីខ្លួន គឺលោក **នួន ជា** "ផ្តល់យោបល់អំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ"។ តំណាងសហព្រះរាជអាជ្ញា **លីសាក់** និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី **ស៊ីម៉ុនណូហ្វត** បានធ្វើការជំទាស់ មិនឲ្យជនជាប់ចោទប្រើប្រាស់ពេលវេលាក្នុងការសួរដេញដោលសាក្សី និងផ្តល់មតិយោបល់ទេ។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យជនជាប់ចោទដាក់សំណួរទៅកាន់សាក្សីតាមរយៈប្រធានតុលាការ យោងតាមវិធាន៩១[34]។ ទោះបីជាយ៉ាងណា ជនជាប់ចោទ **នួន ជា** បានចាប់ផ្តើមអានសេចក្តីថ្លែងការណ៍ដែលទាក់ទងនឹងព្រឹត្តការណ៍ជម្លៀសដោយការបណ្តេញចេញនៅថ្ងៃទី១៧ មេសា ១៩៧៥[35]។ ភ្លាមៗនោះ អង្គជំនុំជម្រះបានបញ្ឈប់ **នួន ជា** និងចុចផ្តាច់មេក្រូហ្វូនសម្លេង។ លោក **នួន ជា** បានបន្តអានសេចក្តី

ថ្លែងការណ៍ខ្លួន ទោះបីជាម៉ៃក្រូហ្វូនសម្លេងពុំមានដំណើរការ និងមិនមានការបកប្រែ។ មេធាវី **ផៃស្តមិន** បាន តវ៉ា និងស្នើសុំថា សេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនគួរត្រូវបកប្រែជាភាសាអង់គ្លេស ប្រធានអង្គជំនុំជម្រះបាន ធ្វើការកត់សម្គាល់ថា ៖

*ជនជាប់ចោទមិនអនុញ្ញាតឲ្យធ្វើសេចក្តីថ្លែងការណ៍ទេ។ គោលបំណងនាពេលនេះ គឺ ស្តាប់សក្ខីកម្មសាក្សី។ លោកអាចធ្វើបែបនេះបាន គឺធ្វើនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ កិច្ចពិភាក្សាដេញដោល។ ប្រសិនបើលោកមិនមានសំណួរសួរទៅសាក្សីទេ សូម លោកអង្គុយចុះ!*

គួរកត់សម្គាល់ ! កាលសប្តាហ៍កន្លងមក អង្គជំនុំជម្រះបានអនុញ្ញាតឲ្យលោក **នួន ជា** ធ្វើការឆ្លើយ តបនឹងសក្ខីកម្មរបស់លោក **ឌុច** ទោះបីជាមានការជំទាស់ពីសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណី[36]។ ករណីនេះលេចចេញថា ការនៅតែអនុវត្តតាមដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០១ ដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក **ឌុច** ធ្វើការផ្តល់យោបល់ បន្ទាប់ពីសក្ខីកម្មសាក្សីនីមួយៗ។ អង្គជំនុំជម្រះ បានធ្វើការផ្លាស់ប្តូរនីតិវិធី ដោយថា សេចក្តីថ្លែងការណ៍នីមួយៗទៅធ្វើនៅក្នុងសេចក្តីដ្ឋានបញ្ចប់សវនាការ ដែលធ្វើនៅចុងក្រោយនៃដំណើរការកាត់សេចក្តី។

### ជ. សេចក្តីព្រមានជាផ្លូវការណ៍ទៅក្រុមមេធាវីការពារក្តីលោក នួន ជា

កាលពីថ្ងៃព្រហស្បតិ៍ មុនពេលជូនដំណឹងពីវិសម្យកាល អង្គជំនុំជម្រះបានចេញសេចក្តីព្រមានជាផ្លូវ ការណ៍ដល់ក្រុមមេធាវីការពារក្តីលោក **នួន ជា** (ផ្តោតសំខាន់ទៅលើមេធាវីអន្តរជាតិ) អង្គជំនុំជម្រះចាត់ទុក ថា "ជាការប្រព្រឹត្តកំហុសវិជ្ជាជីវៈ" រួមមាន៖

- ការរំលោភដោយចេតនាលើសេចក្តីសម្រេចនានា
- ការបញ្ចេញឯកសារសម្ងាត់ ឬលាក់ការសម្ងាត់ទៅសារព័ត៌មាន និង
- ការធ្វើសេចក្តីថ្លែងការណ៍ដោយមិនគោរពតុលាការ ឬមិនស្របតាមនិយាម និងក្រមសីលធ៌ម វិជ្ជាជីវៈ។

អង្គជំនុំជម្រះបានចង្អុលបង្ហាញថា គណៈមេធាវីរបស់មេធាវីការពារក្ដីលោក **នួន ជា** គួរត្រូវពិចារណាពីអំពើទាំងនេះ។ បន្ថែមលើនេះ អង្គជំនុំជម្រះប្រកាសថា វិធាន៣៨(១) ចែងពីការដាក់ពិន័យ ដោយជាឯករាជ្យពីគណៈមេធាវីដើម។ ផ្អែកតាមវិធាន ៣៨(១) បន្ទាប់ពីចេញការព្រមានជាផ្លូវការណ៍ អង្គជំនុំជម្រះអាចដាក់ទណ្ឌកម្ម ឬបដិសេធមិនឲ្យមេធាវីចូលរួមសវនាការ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ ឬរំលោភ ឬរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី។

អង្គជំនុំជម្រះមានអំណាចចេញសេចក្ដីព្រមានជាផ្លូវការណ៍ ផ្អែកតាមវិធាន៣៨។ ទោះបីជា អង្គជំនុំជម្រះមិនបានបញ្ជាក់ឲ្យបានជាក់លាក់ពីអំពើដែលចាត់ទុកថា "ជាកំហុស"[37] ក៏ជាក់ស្ដែង មេធាវីការពារក្ដីលោក **នួន ជា** បានបង្ហាញនូវអកប្បកិរិយាមិនគួរគប្បីជាច្រើនកើតនៅក្នុងសវនាការ។ នៅខែមីនា មេធាវី **ផេស្តមិន** បានស្វាគមន៍អង្គជំនុំជម្រះឲ្យដាក់ពាក្យបណ្ដឹងប្រឆាំងរូបលោកទៅកាន់គណៈមេធាវីនៃប្រទេសហូឡង់ ព្រមទាំងបានផ្ដល់ព័ត៌មានទំនាក់ទំនងលម្អិតនៃគណៈមេធាវីនៃប្រទេសនេះ[38]។ អង្គជំនុំជម្រះបានឆ្លើយតប ដោយខឹងសម្បារចំពោះការលើកឡើងរបស់មេធាវី។ នៅសប្ដាហ៍នេះ មេធាវី **អ៊ីនូហ្ស៊ី** បានពាក់ផ្លាក់សញ្ញានៅលើអាវផាយ ដែលសរសេរថា "ខ្ញុំ ♥ (ស្រឡាញ់) ដាដា" ដែលទង្វើនេះបានធ្វើឲ្យមានប្រតិកម្មពីមេធាវីនាំមុខជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងភ្លាមៗនោះ ប្រធានអង្គជំនុំជម្រះបានបញ្ជាឲ្យមេធាវី **អ៊ីនូហ្ស៊ី** ដកផ្លាកនោះចេញ (មើលត្រង់ចំណុចខាងក្រោម IV.ក)។

## IV. ការគ្រប់គ្រងសវនាការ

កិច្ចដំណើរការនីតិវិធីបានដំណើរការទៅដោយរលូននាសប្ដាហ៍នេះ ថ្វីបើមានបញ្ហាពីឥរិយាបថពុំសមរម្យមួយ និងបញ្ហាការបកប្រែ។ អង្គជំនុំជម្រះបានខិតខំប្រឹងប្រែង ដែលគួរឲ្យកោតសរសើរ ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី ជាលទ្ធផល សវនាការសប្ដាហ៍នេះបានបញ្ចប់សក្ខីកម្មសាក្សីទៅតាមកាលវិភាគនៅរសៀលថ្ងៃព្រហស្បតិ៍។

### ក. ឥរិយាបថក្នុងបន្ទប់សវនាការ

ដូចបានចង្អុលបង្ហាញខាងលើ នៅកិច្ចចាប់ផ្ដើមដំណើរការនីតិវិធីថ្ងៃអង្គារ មេធាវី **ពេជ អង្គ** បានទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះ ទៅលើផ្លាកសញ្ញាមួយពាក់លើអាវផាយរបស់មេធាវី **អ៊ីនូហ្ស៊ី** ដែលមានន័យជាភាសាអង់គ្លេសថា "អាយ" និងសញ្ញា "បេះដូងព៌ណក្រហម" និងពាក្យ "ដាដា" ជាភាសាខ្មែរមានន័យថា ៖ "ខ្ញុំ ❤ (ស្រឡាញ់) ដាដា" ដែលសញ្ញានេះអាចជាផ្លាកសញ្ញាពាណិជ្ជកម្ម ហើយមេធាវីមិនគួរពាក់ទេ។ ជាការឆ្លើយតប **អ៊ីនូហ្ស៊ី** បានថ្លែងថា ផ្លាកសញ្ញានេះ គឺជាសញ្ញាបញ្ជាក់ពីទស្សនៈមនោគមវិជ្ជា មិនមែនជាការផ្សាយពាណិជ្ជកម្មទេ។ អង្គជំនុំជម្រះបានស្នើឲ្យមេធាវីដករូបសញ្ញាចេញ ដោយបានពន្យល់ថា អ្នកតំណាងយុត្តិធម៌ (ដូចជាមេធាវី) គឺមិនអនុញ្ញាតឲ្យពាក់ផ្លាកសញ្ញាអ្វីនៅលើឯកសណ្ឋានខ្លួនឡើយ។ មេធាវី **អ៊ីនូហ្ស៊ី** បានថ្លែងថា គាត់នឹងមិនដកដោយស្ម័គ្រចិត្តទេ ក៏ប៉ុន្តែប្រសិនបើតុលាការបង្គាប់ គាត់នឹងធ្វើតាម។ ភ្លាមៗនោះប្រធានអង្គជំនុំជម្រះ **និល ណុន** បានប្រកាសដោយសម្លេងខ្លាំងៗ "យើង បង្គាប់ឲ្យលោកដកចេញឥឡូវនេះ!"។

ហេតុការណ៍នេះមិនបញ្ចប់ទេ ទោះបីជាមេធាវី **អ៊ីនូហ្ស៊ី** បានដករូបសញ្ញានោះចេញក៏ដោយ។ នៅពេលមេធាវី **អ៊ីនូហ្ស៊ី** បានស្នើសុំអង្គជំនុំជម្រះឲ្យកូនក្ដីខ្លួនទៅតាមដានសវនាការពីចម្ងាយពីបន្ទប់សោត ទស្សន៍ គាត់ក៏បានឆ្លៀតឱកាសបរិយាយថា "ដើម្បីជាកំណត់ត្រា ដាដា គឺជាទស្សនៈនិយម ដាដាយស៊ីម" "ចំពោះការជំទាស់មិនឲ្យពាក់ផ្លាក់នេះ គឺពុំមានហេតុផលសោះ និងជាសេចក្ដីសម្រេចដោយមិនត្រឹមត្រូវ"។ មេធាវីបន្ថែមថា "ផ្លាក់សញ្ញានេះមិនមានន័យថា កុំឲ្យសួរ និងកុំឲ្យឆ្លើយ" ចំណុចនេះហាក់ដូចជាបញ្ជាក់ថា អង្គជំនុំជម្រះយកចិត្តទុកដាក់ជាពិសេសដល់ក្រុមខ្លួន"។ គួរឲ្យភ្ញាក់ផ្អើល! អង្គជំនុំជម្រះមិនឆ្លើយតបនឹងឥរិយាបថឡូកឡឺយរបស់មេធាវីឡើយ។ ផ្ទុយទៅវិញ ប្រធានអង្គជំនុំជម្រះបានសម្រេចទៅតាមសំណើ សុំរបស់ជនជាប់ចោទ **នួន ជា** ដែលសុំទៅតាមដានសវនាការពីបន្ទប់រងចាំ។

ចំណែកឯ ការជំទាស់ពីមេធាវី **វែកគិន** និងមេធាវី **អាង ឧត្ដម** ចំពោះរបៀបនៃការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញា **វើង ហ៊ត់** ពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍របស់សាក្សី (មើលផ្នែកទីIII.ក ខាងលើ)។ ទោះបីជា អង្គជំនុំជម្រះ មិនបានចេញសេចក្ដីសម្រេចទៅលើសេចក្ដីជំទាស់ (ក៏ប៉ុន្តែបានណែនាំសហ-ព្រះរាជអាជ្ញាឲ្យរៀបចំសំណួរឡើងវិញ) និងបានក្រើនរំឭកដល់លោក **វើង ហ៊ត់** ពីការខកខានមិនបានផ្ដល់នូវលេខឯកសារ (ERNs) ជាភាសាអង់គ្លេស និងភាសាបារាំង ដែលធ្វើឲ្យមានស្ថានភាពរញ៉េរញ៉ៃ។

ប្រធានអង្គជំនុំជម្រះបានទូន្មានដោយសំដីធ្ងន់ៗទៅកាន់ព្រះរាជអាជ្ញារូបនេះ ដោយបានប្រើពាក្យថា "វាគួរឱ្យខ្មាសអៀនណាស់" ប៉ុន្តែពាក្យនេះ មិនត្រូវបានបកប្រែជាភាសាអង់គ្លេសទេ។

### ខ. បញ្ហានៃការបកប្រែ និងបញ្ហាបច្ចេកទេស

ការបកប្រែត្រូវបានក្លាយជាបញ្ហាសំខាន់ក្នុងសប្តាហ៍នេះ ភាពមិនត្រឹមត្រូវនៃការបកប្រែបានបង្កឱ្យមានការភ័ន្តច្រឡំនៅក្នុងកិច្ចដំណើរការនីតិវិធី អំពីកាលបរិច្ឆេទ និងតួលេខជាដើម និងការមិនបានបកប្រែជាច្រើនដង ដែលនាំឱ្យធ្វើភាគីសួរសំណួរឡើងវិញ និងសុំការបញ្ជាក់។

### គ. វត្តមាន

មានតែជនជាប់ចោទ **ខៀវ សំផន** ម្នាក់ប៉ុណ្ណោះ មានវត្តមានជានិច្ចកាលនៅក្នុងកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ។ ដោយសារបញ្ហាសុខភាពទ្រុឌទ្រោម ជនជាប់ចោទ **អៀង សារី** ត្រូវបានអនុញ្ញាតឱ្យចូលរួមតាមដានសវនាការពីចម្ងាយពេញមួយសប្តាហ៍។ នៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ជនជាប់ចោទ **នួន ជា** បានបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការតែពេលព្រឹក និងទៅតាមដានសវនាការពីបន្ទប់រងចាំនៅពេលរសៀល។ ចំណែកនៅថ្ងៃពុធ វត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការរហូតដល់វគ្គទី៣ ក្នុងគោលបំណងសួរសំណួរសាក្សី ក៏ប៉ុន្តែ បន្ទាប់ពីអង្គជំនុំជម្រះបានបដិសេធមិនឱ្យគាត់អានទូវសេចក្តីថ្លែងការណ៍ **នួន ជា** បានស្នើសុំអនុញ្ញាតទៅតាមដានសវនាការពីចម្ងាយវិញ ដោយលើកឡើងថា "ប្រសិនបើមិនអនុញ្ញាតឱ្យខ្ញុំបន្តសេចក្តីថ្លែងទេ ខ្ញុំសុំទៅបន្ទប់ខាងក្រោម" (បន្ទប់សោតទស្សន៍)។

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី*** ៖ អាសនៈចំនួន១០ នៅក្នុងបន្ទប់សវនាការ ត្រៀមបម្រុងសម្រាប់ដើមរដ្ឋប្បវេណី គឺបំពេញដោយវត្តមានរបស់ដើមបណ្តឹរដ្ឋប្បវេណី នាសប្តាហ៍នេះ។

***វត្តមានរបស់ភាគី*** ៖ គ្រប់ភាគីមានវត្តមាននៅកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ លើកលែងតែមេធាវី **ម៉ៃឃើល កាណាវ៉ាស** ដែលជាមេធាវីការពារក្តីរបស់ជនជាប់ចោទ **អៀង សារី** អវត្តមានពេញមួយសប្តាហ៍។ តាមរយៈអ្នកឃ្លាំមើលតុលាការ នៅថ្ងៃព្រហស្បតិ៍ មេធាវី **ស៊ីម៉ុនណូហ្វត** មិនមានវត្តមាននៅក្នុងបន្ទប់សវនាការ។

***ការចូលរួមពីសាធារណជន*** ៖ កាលពីថ្ងៃអង្គារ មានប្រជាជន ៣០០នាក់ មកពីខេត្តបាត់ដំបង បានចូលរួមសវនាការពេញមួយព្រឹក។ ពេលរសៀល មានតែភ្ញៀវអន្តរជាតិដែលមានចំនួនតិចតួចប៉ុណ្ណោះ នៅក្នុងសាលសវនាការ។ កាលពីថ្ងៃពុធ មានប្រជាជនប្រមាណជា ១០០នាក់ មកពីស្រុកមុខកំពូល ខេត្តកណ្តាល និង ៣០០នាក់ទៀត មកពីស្រុកបូរីជលសារ ខេត្តតាកែវ បានចូលរួមតាមដានសវនាការរហូតដល់វគ្គទី៣។ នៅថ្ងៃប្រហស្បតិ៍ មានប្រជាជនប្រមាណជា ៥៧០នាក់ មកពីស្រុកមេមត់ ខេត្តកំពង់ចាម មានវត្តមានរហូតវគ្គទី៣ នៃដំណើរការនីតិវិធី។

## ង) តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | ការសម្រាក ពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោង សរុប |
|---|---|---|---|---|---|---|
| ថ្ងៃអង្គារ *១៩/០៦/១២* | ៩:០០ | ១០:៣០-១០:៥៣ | ១២:០៣-១៣:៣០ | ១៤:៤១-១៥:០៣ | ១៦:០៣ | ៤ម៉ោង និង ៥១ នាទី |
| ថ្ងៃពុធ ២០/០៦/១២ | ៩:០១ | ១០:៤៧-១១:០៦ | ១២:០៤-១៣:៣២ | ១៤:៤៩-១៥:០៧ | ១៦:០២ | ៤ម៉ោង និង ៥៦នាទី |
| ថ្ងៃព្រហស្បតិ៍ ២០/០៦/១២ | ៩:០០ | ១០:៣៣-១០:៥១ | ១២:០៤-១៣:៣១ | ១៤:៤៣-១៥:០០ | ១៥:៤២ | ៤ម៉ោង និង ៤០នាទី |

ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ ៖ *៤ ម៉ោង និង៤៩*នាទី

ចំនួនម៉ោងសរុបក្នុងសប្តាហ៍នោះ ៖ *១៤* ម៉ោង និង *២៧*នាទី

*ចំនួនសរុបនៃ ម៉ោង ថ្ងៃ និង សប្តាហ៍ ៖ ៣៣១ ម៉ោង និង ១៨ នាទី*

**៧៧ ថ្ងៃ និង ២៣ សប្តាហ៍**

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes, Adair Fincher, Kounila Keo, Vidjia Phun, Juan Pablo Stein, Alvin Yap, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

1 Mr. Yun Kim's pseudonym is TCW-797

2 Mr. KhievNeou's pseudonym is TCW-321

3 See Trial Chamber. "Next witnesses in current segment of Case 002/01" (15 June 2012). E172/27.1

4 Asked on the identity of the upper echelon, however, the Witnessed replied that it referred to leaders from the sector and districts.

5 The Witness did indicate that there was a food shortage in ChrouyBanteay Village, to which he shared potatoes or bananas, but he said this did not occur in Sambo District.

6 According to Yun Kim, Phan was the Sambo District chief in early 1977, but was subsequently transferred to Kratie, and later on, also arrested.

7 Yun Kim characterized NuonChea as a "good person as a leader…he would like us cadres, to be good cadres ad we had to engage with the people to know the people." The Witness also stated that he knew NuonChea was with the party center and that NuonChea had "supreme authority." When pressed by Simonneau-Fort to elaborate on what the Witness meant by "supreme authority," the Witness simply stated that supreme authority referred to the "supreme leadership level." The Witness did not know much more about NuonChea's role in DK.

8 According to Yun Kim, Voadthonak Commune was established in 1971 when it separated from Kampong Cham Commune in KaohKhnaer Island, one of the biggest islands of Cambodia. It is located on the West side of the Mekong River while Sambo and Kratie Districts are on the East side.

9 Previously, Yun Kim revealed that ChhunYaung alias "Cheth" was transferred to Kratie for committing immoral acts. Cheth allegedly had a special room where he "work[ed] with women," with some of the women dying as a result. The Witness testified that he remembered that Cheth had strangled and (reportedly) raped a district level teacher in 1971 or 1972.

10 Lysak indicated there is an S-21 confession from Ban Sarun alias Kang dated February 1978.

11 Lysak pointed out that from the Case File, Yi, Sector 505 secretary, entered S-21 on 15 March 1978 and signed a confession in April 1978. Yi's wife, Hun Yun alias Ken, a member of the sewing unit committee, was also imprisoned in S-21. Similarly, Kuon, Sector 505 deputy secretary and military chief, entered S-21 on 21 March 1978. His wife, Bun Lei alias Vun, textile squad chief, was also imprisoned in S-21.

12 This appears to be similar to Duch's experience, as Duch testified that he asked Ta Mok permission to "organize" the wedding to his wife. See Asian International Justice Initiative. KRT Trial Monitor [hereinafter **CASE 002 KRT TRIAL MONITOR**]. Issue No. 15, Hearing on Evidence Week 10 (19-21 March 2012).

13 According to the Closing Order, "the Cham are an ethnic minority within Cambodia who share a common language, a common culture and Islam as a common religion." It was one of the groups targeted by the KR. From a demographic report, 36% of the Cham population perished during DK (compared to 18.7% for Khmers). See Office of the Co-Investigating Judges. "Closing Order" (15 September 2010). D427. par.745,747,753. 186.

14 Trapeang Thum Commune was later divided in two and separated by a road: Trapeang Thum Choeung in the North and Trapeang Thum Tboung in the South, where both Khiev Neou and Ta Mok were born.

15 Ta Mok, known as "Brother No. 5," was one of the central figures of the Khmer Rouge. He is a full-rights member of the CPK Standing Committee and the Secretary of the Southwest Zone during DK.

16 According to the Witness, in the early 1940s Ta Mok left the monkhood, married and joined to the Issarak movement. After the Geneva Convention, Ta Mok quit the Issarak and lived as an "ordinary person" in their community. From their discussions, each tried to convince the other of his views: "I convinced him based on Buddhism when he convinced me on his doctrine. However, we were adamant. We were not easily convinced." This changed when KR gained power, with the Witness quipping, "when he had more power, I was convinced. But still, my belief, my background in Buddhism would never be convinced. I am still superior to him in terms of this."

17 This question was met with an objection from Vercken, who stressed that the Witness only stated in the courtroom that he thought the Accused took charge when Vorn Vet was "absent," and did not say "disappeared," since the latter term has a different connotation. Judge Lavergne clarified that in the French version of his OCIJ statement, the Witness did indeed state that, "after Vorn Vet disappeared approximately in 1977, Khieu Samphan succeeded Vorn Vet for being (sic) in charge of foreign trade. I was told that Vorn Vet was arrested for being involved with the KGB and the CIA." Judge Lavergne commented, "what is abundantly clear is following Vorn Vet's disappearance, Khieu Samphan succeeded Vorn Vet in foreign trade." Curiously, records indicate that Vorn Vet was not arrested until November 1978, near the end of the regime. See Office of the Co-Investigating Judges. "Closing Order" (15 September 2010). D427**.** 425.110. Also Ben Kiernan. The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge, 1975-1979. Second edition. Chiang Mai, Thailand: Silkworm Books. 437.

18 While the Witness did not know what happened to Chou Chet and his wife Im Len, alias Li, Pros. Lysak indicated that in S-21 documents, the two KR leaders were arrested and included in the prisoner lists of S-21.

[19] Nonetheless, the Witness also recounted that there were some monks who went to Pchet Chrum Pagoda and practiced Buddhism for about a year. Eventually, these monks also disrobed, and people did not go to the pagodas anymore as "Buddhists went to the pagoda because there were monks."

[20] The Witness however related that he heard recently of a certain monk from Kirivong who resisted disrobing and instead hanged himself.

[21] Trial Chamber. "Notice to parties regarding revised modalities of questioning and Response to Co-Prosecutors' Request for Clarification Regarding the Use of Documents During Witness Testimony" (13 June 2012). E201/2.

[22] Ibid. at par. 1. 1.

[23] Ibid. at par. 1. 1.

[24] Despite Judge Lavergne's explanation, Ang Udom still expressed reservations on the necessity of reading the statement and then putting questions, as this may be classified as a leading question. This point remained unaddressed, with the President only asking Veng Huot to rephrase his question to avoid objections.

[25] Notably, when the Trial Chamber asks witnesses to recall their previous OCIJ testimonies, they were not provided with the statements and the chance to review them again inside the courtroom. Although it was mentioned that they reviewed the statements before entering the courtroom, the circumstances on how this was made, or if the witness is aware that this is the document referred to by the Chamber subsequently in the courtroom, are unknown.

[26] This probably is in reference to the part of Khiev Neou's OCIJ statement read out by Judge Lavergne in court, see endnote 21 above.

[27] In response to Vercken's submission, Judge Lavergne merely asked the counsel, "Is what I just read contrary to what was recorded? Does it contradict what Mr. Khiev Neou stated to the investigators?"

[28] See Nuon Chea Defense Team. "Rule 87 Request to Put New Evidence to TCW-797 for Impeachment Purposes" (18 June 2012). E209.

[29] Ibid. at p. 1, footnote 1, citing Office of the Co-investigative Judges. "Order on Co-Prosecutors' Requests for Investigative Action" (12 January 2010). D303.

[30] The Chamber allowed questions on the document, but with the caveat that it will exercise the discretion to disallow irrelevant questions.

[31] See Nuon Chea Defense Team. "Rule 87 Request to Put New Evidence to TCW-321 for Impeachment Purposes" (19 June 2012). E210.

[32] Judge Cartwright commented that the Nuon Chea Defense did not submit any document list.

[33] See CASE 002 KRT TRIAL MONITOR. Issue No. 26, Hearing on Evidence Week 21 (11-14 June 2012).

[34] As provided under **Rule 29** of the Internal Rules.

[35] Internal Rule 91 on hearing of other parties and witnesses provides:

> xxx
>
> 2. The Judges may ask any questions and the Co-Prosecutors and all the other parties and their lawyers shall also be allowed to ask questions with the permission of the President. Except for questions asked by the Judges, the Co-Prosecutors and the lawyers, all questions shall be asked through the President of the Chamber.

[36] Mr. Nuon Chea's statement, as read in Court, states thus:

> My respect to my compatriots. My respect to Mr. President. I'd like to talk about the forced evacuation of people. I'd like to make some responses to the testimony of this witness and for the witnesses so far that have been heard with regards to the evacuation of people. Mr. Witness has provided some reasonable reasons for the evacuation of people from cities, that is, to avoid the bombardment by the United States and the starvation and the internal wars. However, many of the witnesses do not know the real reasons or more reasons than that, which does seem to show that the means of evacuation was ill-intent. I'd like to make the following responses. First of all, I'd like to state that we are the war losers and we have been accused of forced evacuation of people. However, the current activities are inappropriate if compared to the evacuation conducted after 17 April, 1975. I'd like to make my statement to the poor people who have been oppressed, who have been persecuted and threatened of their lives by the rich, by the powerful, who are robbing their farmland and rice fields.

[37] See CASE 002 KRT TRIAL MONITOR. Issue No. 19, Hearing on Evidence Week 14 (18-20 April 2012).

[38] The Trial Chamber subsequently released a written Decision on the Nuon Chea counsels' misconduct and forwarded written complaints to the Amsterdam Bar Association and the New York State Supreme Court. See Trial Chamber. "Decision on Nuon Chea Defence Counsel Misconduct" (29 June 2012). E214.; Trial Chamber. "Professional misconduct of lawyer[s] admitted to your Bar Association" (29 June 2012). E214/1.